

អង្គាធរមីន
C.M.A.A

គោលការណ៍ណែនាំថ្នាក់ជាតិ
ស្តីពី
កិច្ចសង្គ្រោះជនរងគ្រោះដោយសារ
យុទ្ធភណ្ឌគ្រឿងផ្ទុះ



អាជ្ញាធរមីន
C.M.A.A

គោលការណ៍ណែនាំថ្នាក់ជាតិ

ស្តីពី

កិច្ចសង្គ្រោះជនរងគ្រោះដោយសារ

យុទ្ធភណ្ឌគ្រឿងផ្ទុះ

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មី ផ្លូវលេខ២៧៣ កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
អ៊ីមែល: info@cmaa.gov.kh
គេហទំព័រ: www.cmaa.gov.kh

មាតិកា

អារម្ភកថា
សេចក្តីថ្លែងអំណរគុណ
អក្សរកាត់
ពាក្យគន្លឹះ និង និយមន័យ
ជំពូកទី១៖ សេចក្តីផ្តើម
- គោលបំណងនៃគោលការណ៍ណែនាំ
- វិសាលភាព និងការអនុវត្ត
- ក្របខ័ណ្ឌច្បាប់

ជំពូកទី២៖ គោលការណ៍នៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធតណ្ហាគ្រឿងផ្ទុះ
- ការមិនរើសអើង
- ការចូលរួមនិងការធ្វើបរិយាបន្ន
- ភាពងាយស្រួល
- ភាពងាយរងគ្រោះ
- អាយុ យេនឌ័រ ពិការភាព និងការពិចារណាពីភាពចម្រុះ
- និរន្តរភាពនិងការទទួលខុសត្រូវថ្នាក់ជាតិ
- វិធីសាស្ត្រផ្អែកលើសិទ្ធិ
- អនុវត្តផ្អែកលើកស្តុតាង

ជំពូកទី៣៖ សមាសធាតុនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធតណ្ហាគ្រឿងផ្ទុះ
- ការប្រមូលទិន្នន័យ
- ការសង្គ្រោះបន្ទាន់និងថែទាំវេជ្ជសាស្ត្របន្ត
- ការស្តារលទ្ធភាពពលកម្ម
- ការគាំទ្រផ្លូវចិត្តនិងចិត្តសង្គម
- បរិយាបន្នសេដ្ឋកិច្ច សង្គម
- ច្បាប់និងគោលនយោបាយ

ជំពូកទី៤៖ វិធីសាស្ត្រពហុវិស័យ (កិច្ចសហការរួមគ្នា)
- សេវាថែទាំសុខភាពនិងវេជ្ជសាស្ត្រ
- ការស្តារលទ្ធភាពពលកម្ម
- ការគាំទ្រផ្លូវចិត្ត
- បរិយាបន្នសេដ្ឋកិច្ច សង្គម
- ការអប់រំ
- ការប្រគល់អំណាច
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ

- ការងារ
- ប្រព័ន្ធគាំពារសង្គម(ជំនួយសង្គមនិងសន្តិសុខសង្គម)
- ជំនួយផ្នែកច្បាប់
- ការបណ្តុះបណ្តាលជំនាញសង្គ្រោះបឋម និងព្យាបាលដោយកញ្ចក់

ជំពូកទី៥៖ ការសម្របសម្រួល កិច្চសហការ និងការអនុវត្ត

- តួនាទីរបស់អាជ្ញាធរមីន
- តួនាទីរបស់ស្ថាប័នរដ្ឋាភិបាល
- តួនាទីប្រតិបត្តិករសកម្មភាពមីន
- តួនាទីអង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល និង សង្គមស៊ីវិល
- យន្តការកិច្চសហប្រតិបត្តិការអន្តរជាតិនិងការផ្តល់មូលនិធិសម្រាប់ជួយដល់ជនរងគ្រោះ
- ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ

ជំពូកទី៦៖ ក្របខ័ណ្ឌច្បាប់សម្រាប់កិច្চសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

- ក្របខ័ណ្ឌច្បាប់និងអនុសញ្ញាអន្តរជាតិសម្រាប់កិច្চសង្គ្រោះជនរងគ្រោះ
- ក្របខ័ណ្ឌច្បាប់និងគោលនយោបាយជាតិសម្រាប់កិច្চសង្គ្រោះជនរងគ្រោះ

ជំពូកទី៧៖ បញ្ហាប្រឈម ទិសដៅអនុវត្តសកម្មភាពបន្ត និង អនុសាសន៍

- បញ្ហាប្រឈម
- ទិសដៅអនុវត្តសកម្មភាពបន្ត
- អនុសាសន៍

ជំពូកទី៨៖ ការត្រួតពិនិត្យនិងវាយតម្លៃ

- ទំនួលខុសត្រូវរបស់អាជ្ញាធរមីន
- ទំនួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាល
- ទំនួលខុសត្រូវរបស់ប្រតិបត្តិករសកម្មភាពមីន
- ទំនួលខុសត្រូវរបស់អ្នកផ្តល់សេវាគាំទ្រ

ជំពូកទី៩៖ សេចក្តីសន្និដ្ឋាន និងការអំពាវនាវ

- សង្ខេបចំណុចសំខាន់ៗ
- អំពាវនាវឱ្យមានសកម្មភាពសម្រាប់ការបន្តការប្តេជ្ញាចិត្ត
- ការទទួលស្គាល់ភាគីពាក់ព័ន្ធនិងដៃគូ

ឯកសារយោង

ឧបសម្ព័ន្ធ "ក"

- តារាងត្រួតពិនិត្យនៃការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្চសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អារម្ភកថា

ក្នុងរយៈពេលជាងបីទសវត្សរ៍កន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់នូវដំណាក់កាលផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់ ពីប្រទេសដែលរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារជាននៃសង្គ្រាម មកជាប្រទេសដែលមានសុខសន្តិភាពពេញលេញ និងមានការអភិវឌ្ឍយ៉ាងរហ័សលើគ្រប់វិស័យ។ ទោះជាយ៉ាងណាក៏សំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលនៅសេសសល់ពីអតីតកាល នៅតែបន្តជាឧបសគ្គដ៏ចម្បងមួយចំពោះសុវត្ថិភាពសាធារណៈ និងជាការរំខានដល់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ជាពិសេសជនរងគ្រោះដែលបានបាត់បង់អវយវៈ ឬរងការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរពីផលប៉ះពាល់នៃគ្រឿងផ្ទុះទាំងនោះ។

ការរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនេះឡើង គឺមានគោលបំណងឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍ ក៏ដូចជាប្រតិបត្តិករសកម្មភាពមីនទាំងអស់ ក្នុងការផ្តល់នូវការគាំពារ និងការលើកកម្ពស់សិទ្ធិសេរីភាពជូនដល់ជនរងគ្រោះគ្រប់រូប។ កិច្ចសង្គ្រោះជនរងគ្រោះ មិនមែនគ្រាន់តែជាការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រមួយគ្រានោះទេ ប៉ុន្តែវាគឺជា «បេសកកម្មមនុស្សធម៌» ដែលត្រូវដើរទន្ទឹមគ្នាជាមួយ «ការអភិវឌ្ឍសង្គម» តាមរយៈការកសាងប្រព័ន្ធគាំទ្រមួយដែលរឹងមាំ ប្រកបដោយសមធម៌ និងបរិយាបន្ន ដើម្បីជានាថាជនរងគ្រោះអាចរស់នៅដោយមានឯករាជ្យភាព និងមានឱកាសពេញលេញក្នុងការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សង្គមជាតិ។

ខ្លឹមសារដែលមាននៅក្នុងជំពូកនីមួយៗនៃឯកសារនេះ បានបង្ហាញយ៉ាងច្បាស់នូវក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិ ផែនការយុទ្ធសាស្ត្រ កិច្ចប្រតិបត្តិការ បញ្ហាប្រឈមជាប្រព័ន្ធដែលនៅសេសសល់ និងទិសដៅអនុសាសន៍គោលនយោបាយសម្រាប់អនាគត។ យើងជឿជាក់យ៉ាងមុតមាំថា ការវិភាគស៊ីជម្រៅលើបញ្ហាទាំងនេះ នឹងក្លាយជាគ្រឹះវិស័យដ៏សំខាន់សម្រាប់តម្រង់ទិសដល់ភាគីពាក់ព័ន្ធ ម្ចាស់ជំនួយ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការរួមគ្នាដោះស្រាយគម្លាតនៃសេវាគាំទ្រ និងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះជនមានពិការភាព។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហគមន៍ជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងសប្បុរសជនទាំងអស់ ដែលបានបន្តគាំទ្រទាំងស្មារតី និងធនធានដល់វិស័យសកម្មភាពមីនក៏ដូចជាវិស័យពិការភាពនៅកម្ពុជា។ ជាពិសេសបំផុត ខ្ញុំសូមសម្តែងនូវការគោរព និងកោតសរសើរចំពោះភាពរឹងមាំ និងមនសិការតស៊ូរបស់ជនរងគ្រោះគ្រប់រូប ដែលជាកម្លាំងចលករដ៏មានឥទ្ធិពល បំផុសឱ្យយើងទាំងអស់គ្នាកាន់តែខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ «កម្ពុជាគ្មានមីន និងបរិយាបន្នសម្រាប់មនុស្សគ្រប់រូប» ក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

ថ្ងៃព្រហស្បតិ៍ ១០រោចខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០២៦
ទេសរដ្ឋមន្ត្រីជួលបន្ទុកបេសកកម្មពិសេស
អនុប្រធានទី១ អាជ្ញាធរមីន

បណ្ឌិត លី ធុជ

សេចក្តីថ្លែងអំណរគុណ

ការរៀបចំ និងការបញ្ចប់ដោយជោគជ័យនៃ «ឯកសារគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ» នេះ គឺជាសមិទ្ធផលរួមដ៏វិសេសវិសាល ដែលកើតចេញពីកិច្ចសហការយ៉ាងស្អិតរមួត និងការប្តេជ្ញាចិត្តខ្ពស់ពីសំណាក់ស្ថាប័នរដ្ឋ ប្រតិបត្តិករ ដៃគូអភិវឌ្ឍន៍ និងបុគ្គលពាក់ព័ន្ធជាច្រើនរូប ដែលបានចូលរួមជាកម្លាំងកាយ ប្រាជ្ញា និងស្មារតី ដើម្បីបុព្វហេតុការងារមនុស្សធម៌ និងការលើកកម្ពស់សិទ្ធិជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា។

ជាដំបូង យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ រាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរមីន ដែលបានផ្តល់នូវការតម្រង់ទិសយុទ្ធសាស្ត្រ ការសម្របសម្រួល និងការគាំទ្រផ្នែកបច្ចេកទេសយ៉ាងយកចិត្តទុកដាក់បំផុត។ ការដឹកនាំដ៏ឈ្លាសវៃនេះ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់សុវត្ថិភាព និងការអភិវឌ្ឍសង្គមជាតិប្រកបដោយបរិយាបន្ន។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងក្រុមប្រឹក្សាសកម្មភាពជនពិការ និងមូលនិធិជនពិការ ដែលបានខិតខំប្រឹងប្រែងក្នុងការតាក់តែងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីកិច្ចការពារសិទ្ធិ និងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ជនមានពិការភាពឱ្យកាន់តែមានភាពល្អប្រសើរឡើងជាលំដាប់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ប្រតិបត្តិករជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ ប្រទេសម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ទាំងអស់ ដែលបានផ្តល់ជូនជាថវិកា និងជំនាញឯកទេស ក្នុងការអនុវត្តកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះ ការផ្តល់ឧបករណ៍ជំនួយ ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការគាំទ្រផ្នែកផ្លូវចិត្ត និងចិត្តសង្គម និងការគាំទ្រផ្នែកសេដ្ឋកិច្ច សង្គម ដែលបានផ្លាស់ប្តូរជីវិតរស់នៅរបស់ជនរងគ្រោះឱ្យមានក្តីសង្ឃឹម និងមានឯករាជ្យភាពជាថ្មី។

ជាពិសេស យើងខ្ញុំសូមអរគុណដល់ក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានសង្គ្រោះជនពិការដោយសារមីននៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីនទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចងក្រង ប្រមូលនិងផ្តល់ព័ត៌មាន ទិន្នន័យ និងការវិភាគស៊ីជម្រៅ ដែលជាធាតុចូលដ៏សំខាន់មិនអាចខ្វះបាន ក្នុងការធ្វើឱ្យខ្លឹមសារនៃឯកសារនេះមានភាពគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈវិទ្យាសាស្ត្រខ្ពស់។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពកោតសរសើរ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ និងជនមានពិការភាពគ្រប់រូប ដែលបានផ្តល់នូវមតិយោបល់ និងការចែករំលែកបទពិសោធន៍អំពីជីវិតពិត។ ភាពរឹងមាំ និងមនសិការតស៊ូរបស់បងប្អូន គឺជាកម្លាំងចិត្តដ៏មហិមា និងជាមូលហេតុចម្បងដែលអាចជំរុញឱ្យយើងទាំងអស់គ្នា បន្តបេសកកម្មនេះរហូតសម្រេចបាននូវសង្គមមួយដែលប្រកបដោយសមធម៌ បរិយាបន្ន និងការផ្តល់តម្លៃដល់មនុស្សជាតិគ្រប់រូបជានិរន្តរ៍។

អក្សរកាត់

រ.រ.ក.ក. : រាជរដ្ឋាភិបាលកម្ពុជា
អ.ធ.ម. : អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
ក.ស.ជ.ព. : ក្រុមប្រឹក្សាសកម្មភាពជនពិការ
ស.អ.យ. : ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ស.ក. : ក្រសួងសុខាភិបាល
អ.យ.ក. : ក្រសួងអប់រំ យុវជន និងកីឡា
ជ.ន.ស. : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក.ប.វ. : ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
អ.ស.ប. : អង្គការសហប្រជាជាតិ
យូអិនឌីភី : កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
យូនីសេហ្វ : មូលនិធិកុមារនៃអង្គការសហប្រជាជាតិ
អ.ស.ព. : អង្គការសុខភាពពិភពលោក
អាយឡូ : អង្គការពលកម្មអន្តរជាតិ
អូអេចស៊ីអេចអរ : ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ
គ.អ.ច. : គោលជៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
គ.ន.ជ.ស.ម. : គោលនយោបាយជាតិស្តីពីសកម្មភាពមីន
ផ.យ.អ.ជ. : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
ផ.យ.ជ.ព. : ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព
អ.ស.ជ. : អនុសញ្ញាស្តីពីសិទ្ធិជនពិការ
អ.ហ.ផ.ម. : អនុសញ្ញាស្តីពីការហាមឃាត់ការប្រើប្រាស់ ការស្តុកទុក ការផលិត និងការផ្ទេរមីនប្រឆាំងមនុស្ស (អនុសញ្ញាអូតាវ៉ា)
អ.គ.ច. : អនុសញ្ញាស្តីពីគ្រាប់បែកចង្កោម
ស.ក.ម.ក. : ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា
ស.ក.ម.អ. : ស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ
ស.ប.ប.ក. : ស្តង់ដាបទដ្ឋានប្រតិបត្តិការ
អ.ម.រ. : អង្គការមិនមែនរដ្ឋាភិបាល
ក្រុមវ៉ាស៊ីនតោន : កម្រងសំណួរស្តង់ដាអន្តរជាតិសម្រាប់កំណត់អត្តសញ្ញាណជនមានពិការភាព
យ.គ.ផ. : យុទ្ធកណ្តាគ្រឿងផ្ទុះ
យ.ម.ផ. : យុទ្ធកណ្តាមិនទាន់ផ្ទុះ
អ.ជ.ព. : អង្គការជនពិការ
ជ.ព. : ជនមានពិការភាព

ពាក្យគន្លឹះ និងនិយមន័យ

- **<u>យុទ្ធភណ្ឌគ្រឿងផ្ទុះ</u>** : សំដៅលើគ្រឿងផ្ទុះគ្រប់ប្រភេទដែលនៅសេសសល់ពីសង្គ្រាម រួមមានគ្រាប់មីនប្រឆាំងមនុស្ស មីនប្រឆាំងរថក្រោះ គ្រាប់បែកចង្កោម គ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ(UXO) និងយុទ្ធភណ្ឌដទៃទៀតដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិត
- **<u>ជនរងគ្រោះ</u>** : ក្នុងបរិបទនៃឯកសារនេះ ជនរងគ្រោះមិនមែនសំដៅតែលើបុគ្គលដែលរងរបួសដោយផ្ទាល់នោះទេ ប៉ុន្តែរួមមាន៖
    - បុគ្គលរងគ្រោះ : អ្នកដែលរងរបួស បាត់បង់សរីរាង្គ ឬពិការភាព
    - ក្រុមគ្រួសារ : សាច់ញាតិដែលរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងផ្លូវចិត្ត
    - សហគមន៍រងគ្រោះ : សហគមន៍ដែលរងការខាតដល់ការរស់នៅ និងការអភិវឌ្ឍ ដោយសារវត្តមានគ្រឿងផ្ទុះ
- **<u>ជនរងគ្រោះដោយផ្ទាល់</u>** : សំដៅលើមនុស្សស្លាប់ របួស និងពិការដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- **<u>អ្នករស់រានមានជីវិត</u>** : សំដៅលើជនរងគ្រោះដោយផ្ទាល់ដែលបានរងរបួស ឬពិការ ប៉ុន្តែមិនបានស្លាប់ដោយសាររងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- **<u>ជនរងគ្រោះដោយប្រយោល</u>** : សំដៅលើសមាជិកគ្រួសារនៃជនរងគ្រោះដោយផ្ទាល់ ក៏ដូចជាបុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- **<u>កិច្ចសង្គ្រោះជនរងគ្រោះ</u>** : គឺជាបេសកកម្មមនុស្សធម៌ និងការអភិវឌ្ឍសង្គមដែលផ្តល់នូវការគាំពារ ការព្យាបាលវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការគាំទ្រផ្លូវចិត្ត និងការលើកកម្ពស់សិទ្ធិសេរីភាពជូនដល់ជនរងគ្រោះគ្រប់រូប ដើម្បីឱ្យពួកគេអាចរស់នៅដោយមានឯករាជ្យភាព
- **<u>បរិយាបន្ន</u>** : ការធានាថាជនរងគ្រោះ និងជនមានពិការភាពមានឱកាសពេញលេញ និងស្មើភាពក្នុងការចូលរួមក្នុងសកម្មភាពសង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ដោយគ្មានការរើសអើង
- **<u>បរិយាបន្នសេដ្ឋកិច្ច សង្គម</u>** : សំដៅលើការអប់រំប្រកបដោយបរិយាបន្ន និងបរិយាបន្នសេដ្ឋកិច្ច ដូចជា ការផ្តល់ប្រាក់ឈ្នួលស្មើគ្នា ផ្តល់យុត្តិធម៌ និងឱកាសសម្រាប់ទទួលការងារសមរម្យ ក៏ដូចជាការបណ្តុះបណ្តាល ជំនាញការអប់រំជ្នាជីវៈ កិច្ចគាំពារសង្គម ការងារប្រកបដោយនិរន្តរភាព។ល។ ក៏ដូចជាការធ្វើការងារដោយខ្លួនឯង និងរួមបញ្ចូលកិច្ចគាំពារសង្គមផងដែរ
- **<u>ការស្តារលទ្ធភាពពលកម្ម</u>** : ដំណើរការជួយឱ្យជនរងគ្រោះទទួលបានមកវិញនូវសមត្ថភាពផ្នែករាងកាយ និងមុខងារសរីរាង្គកាយ តាមរយៈការព្យាបាលដោយចលនា និងការបំពាក់ឧបករណ៍ជំនួយ(ដូចជាអវយវៈសិប្បនិម្មិត) ដើម្បីឱ្យពួកគាត់អាចបំពេញការងារ និងរស់នៅបានប្រសើរឡើង
- **<u>ការគាំទ្រផ្លូវចិត្តនិងចិត្តសង្គម</u>** : សេវាប្រឹក្សាយោបល់ និងការព្យាបាលដើម្បីជួយជនរងគ្រោះឱ្យជម្នះបាននូវរបិត្តិផ្នែកស្មារតី ការតក់ស្លុត និងបង្កើនភាពរឹងមាំផ្នែកអារម្មណ៍ ដើម្បីវិលត្រឡប់ទៅរកជីវភាពរស់នៅជាធម្មតាវិញ

- **<u>សមធម៌</u>** : ការផ្តល់សេវា ឬជំនួយដោយផ្អែកលើតម្រូវការជាក់ស្តែងរបស់បុគ្គលម្នាក់ៗ ដើម្បីធានាថាអ្នកគ្រប់គ្នាទទួលបានលទ្ធផលប្រហាក់ប្រហែលគ្នា ទោះបីជាពួកគេមានស្ថានភាពចាប់ផ្តើមខុសគ្នាក៏ដោយ
- **<u>ភាពងាយស្រួល</u>** : ការលុបបំបាត់រាល់ឧបសគ្គ(រូបវន្ត ព័ត៌មាន និងច្បាប់) ដើម្បីឱ្យជនមានពិការភាពអាចចូលប្រើប្រាស់សេវាកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងព័ត៌មាននានាបានដោយងាយស្រួល និងសុវត្ថិភាព
- **<u>វិធីសាស្ត្រពហុវិស័យ</u>** : ដោះស្រាយបញ្ហាជនរងគ្រោះដោយមានការចូលរួមពីគ្រប់វិស័យពាក់ព័ន្ធ (ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) មិនមែនតែវិស័យសកម្មភាពមីនមួយមុខនោះទេ
- **<u>កស្តុតាងជាក់ស្តែង</u>** : ការផ្តល់សេវាដែលផ្អែកលើការសិក្សាស្រាវជ្រាវ ទិន្នន័យត្រឹមត្រូវ និងតម្រូវការពិតប្រាកដរបស់ជនរងគ្រោះ ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពខ្ពស់
- **<u>បញ្ជូន</u>** : សំដៅលើការផ្តល់ព័ត៌មានអំពីសេវាដែលមានដល់ជនរងគ្រោះ
- **<u>យន្តការបញ្ជូនបន្ត</u>** : សំដៅលើប្រព័ន្ធសម្រាប់កំណត់អត្តសញ្ញាណ កិច្ចការពារ និងជួយជនរងគ្រោះដែលរងរបួសដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អ្នករស់រានមានជីវិត ជនមានពិការភាព និងជនរងគ្រោះដោយប្រយោល ហើយភ្ជាប់ពួកគេទៅកាន់សេវាផ្តល់ជំនួយដល់ជនរងគ្រោះដែលត្រូវការ ឬផ្តល់ឱ្យពួកគេនូវ «ព័ត៌មានអំពីសេវាកម្មដែលមាន»។

ជំពូកទី១៖ សេចក្តីផ្តើម

គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ គឺជាឯកសារដែលត្រូវបានរៀបចំឡើងដោយធ្វើសមាហរណកម្មអន្តរវិស័យ ដើម្បីគាំទ្រដល់ជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះនៅក្នុងប្រទេសកម្ពុជា។

អាជ្ញាធរមីន ដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងតាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗបានរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិនេះឡើង ក្នុងគោលបំណងតម្រង់ទិសដល់គ្រប់អង្គការ ប្រតិបត្តិករ និងស្ថាប័នទាំងឡាយណាដែលផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះនៅកម្ពុជា។ កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ គឺជាអាទិភាពចម្បងរបស់អាជ្ញាធរមីន និងដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងក្នុងរយៈពេលខ្លី មធ្យម និងវែង សម្រាប់ជនរងគ្រោះដែលទទួលរងផលប៉ះពាល់ទាំងផ្នែកសរីរាង្គកាយ ផ្លូវចិត្ត និងសតិអារម្មណ៍ ព្រមទាំងក្រុមគ្រួសារ និងសហគមន៍ដែលរងគ្រោះ ដែលទាមទារឱ្យមានវិធីសាស្ត្រ «អន្តរវិស័យ» ដោយផ្អែកលើការគោរពសិទ្ធិ និងការធ្វើបរិយាបន្ន។

ក្នុងនាមជាអ្នកសម្របសម្រួល អាជ្ញាធរមីនដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញដល់ក្រសួង ស្ថាប័ន ប្រតិបត្តិករ និងអង្គការនានា ឱ្យផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយគិតគូរពីកត្តា អាយុ យេនឌ័រ និងពិការភាព។ ទន្ទឹមនឹងនេះ អាជ្ញាធរមីន សូមលើកទឹកចិត្តដល់គ្រប់ក្រសួង ស្ថាប័ន ប្រតិបត្តិករ និងអង្គការពាក់ព័ន្ធទាំងអស់ យកឯកសារគោលការណ៍ណែនាំនេះទៅអនុវត្តឱ្យស្របតាមការណែនាំជាក់ស្តែង។

គោលបំណង

គោលបំណងនៃគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ រួមមានចំណុចសំខាន់ៗដូចខាងក្រោម៖

- តម្រង់ទិស និងគាំទ្រដល់អង្គការ ឬស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ និងជាក់លាក់អំពីសេវាកម្ម វិធីផ្តល់ជំនួយដល់ជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ
- ផ្តល់ការណែនាំផ្នែកបច្ចេកទេសដល់ប្រតិបត្តិករសកម្មភាពមីន ភាគីពាក់ព័ន្ធ និងសហគមន៍ឱ្យបានទូលំទូលាយ ដើម្បីយកទៅរៀបចំជាស្តង់ដាបទដ្ឋានប្រតិបត្តិការ ផែនការសកម្មភាព គម្រោងថវិកា និងយកធ្វើជាផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះឱ្យមានប្រសិទ្ធភាព។

វិសាលភាព និង ការអនុវត្ត

ឯកសារនេះបានកំណត់អំពីវិសាលភាពនៃខ្លឹមសារ និងការណែនាំបច្ចេកទេសនៃគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ។ គោលការណ៍ណែនាំនេះ ផ្តល់នូវទិសដៅច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវសម្រាប់ភាគីពាក់ព័ន្ធ រួមមាន អាជ្ញាធរមីន ស្ថាប័នរដ្ឋាភិបាល អង្គការសហប្រជាជាតិ ប្រតិបត្តិករសកម្មភាពមីននិងអង្គការផ្តល់សេវាដទៃទៀត។ ជារួមកិច្ចសង្គ្រោះជនរងគ្រោះគឺជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលដោយមានអាជ្ញាធរមីនជាអ្នកសម្របសម្រួល។

ជាទូទៅ ជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ តែងមានតម្រូវការលើសេវាសង្គ្រោះបន្ទាន់ ការថែទាំវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការអប់រំ និងការធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម ដែលសេវាទាំងនេះភាគច្រើនស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិស័យផ្សេងៗ ក្រៅពីវិស័យសកម្មភាពមីន។

គោលការណ៍អនុវត្ត៖ ការគាំទ្រទាំងនេះ ត្រូវផ្តល់ជូនស្របតាមបទដ្ឋាន និងស្តង់ដាដែលមានស្រាប់ក្នុងវិស័យពាក់ព័ន្ធ ដូចជា៖

- វិស័យសុខាភិបាល និងការស្តារលទ្ធភាពពលកម្មកាយសម្បទា
- វិស័យពិការភាព និងកិច្ចគាំពារសង្គម
- វិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- វិស័យអភិវឌ្ឍន៍ និងការងារ
- វិស័យសំណង់ និងសាធារណការ

ការអនុវត្តនេះ ត្រូវធ្វើឡើងឱ្យស្របតាមច្បាប់ គោលនយោបាយ នីតិវិធី និងគោលការណ៍ណែនាំជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍ណែនាំនេះ នឹងក្លាយជាឧបករណ៍ដ៏សំខាន់ក្នុងការតម្រង់ទិស និងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តការងារក្នុងផ្នែកកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ។

ក្របខ័ណ្ឌច្បាប់

ការអនុវត្តកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាគ្រឿងផ្ទុះ ត្រូវអនុលោមតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិជាធរមាន ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់។ ក្នុងនោះ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាបាននូវសិទ្ធិសេរីភាព ការមិនរើសអើង និងការផ្តល់ឱកាសស្មើៗគ្នាដល់ជនមានពិការភាពគ្រប់រូបនៅក្នុងសង្គម។ ទន្ទឹមនឹងនេះ ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់មីនប្រឆាំងមនុស្ស(អនុសញ្ញាអូតាវ៉ា) កម្ពុជាមានភាតព្វកិច្ចយ៉ាងសកម្មក្នុងការផ្តល់ជំនួយ និងការសង្គ្រោះដល់ជនរងគ្រោះថ្នាក់ដោយសារមីន។

ជាមួយគ្នានេះដែរ ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ ក៏បានសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគោរពសិទ្ធិជាមូលដ្ឋាន និងការធ្វើបរិយាបន្នដល់ជនមានពិការភាពទៅក្នុងគ្រប់សកម្មភាពអភិវឌ្ឍ។ ដើម្បីតម្រង់ទិសការអនុវត្តឱ្យមានលក្ខណៈស្របគ្នា ឯកសារនេះក៏ផ្តែកលើ គោលនយោបាយជាតិសកម្មភាពមីន និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ព្រមទាំងគោរពតាមបទដ្ឋានបច្ចេកទេសដែលមានចែងនៅក្នុងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាជំពូកទី២៣ ដែលកំណត់អំពីនីតិវិធីប្រតិបត្តិការស្តង់ដាក្នុងវិស័យសកម្មភាពមីនទាំងមូល។

ជំពូកទី២៖ គោលការណ៍នៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

មូលដ្ឋានគ្រឹះនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍មនុស្សធម៌ជាសកល រួមមាន ភាពជាមនុស្សធម៌ អព្យាក្រឹតភាព ភាពមិនលម្អៀង និងឯករាជ្យភាព។ រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ បានកំណត់យកការផ្តល់ជំនួយ និងការគាំទ្រដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះជាកិច្ចការអាទិភាព។ រាល់សកម្មភាពនៃកិច្ចសង្គ្រោះជនរងគ្រោះត្រូវបានរៀបចំឡើងដោយការពិចារណា និងគិតគូរលើទិដ្ឋភាពជាក់ស្តែង និងអនុវត្តឱ្យស្របតាមច្បាប់មនុស្សធម៌ សិទ្ធិមនុស្សជាតិ និងអន្តរជាតិ ព្រមទាំងស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ និងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។

គោលការណ៍ទូទៅនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបានកំណត់យ៉ាងលម្អិតនៅក្នុងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាជំពូកទី២៣ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- **<u>ការមិនរើសអើង</u>** : កិច្ចសង្គ្រោះត្រូវអនុវត្តដោយស្មើភាព ដោយមិនបែងចែករវាងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងជនមានពិការភាពដោយមូលហេតុផ្សេងៗឡើយ។ រាល់ការគាំទ្រត្រូវផ្អែកលើតម្រូវការជាក់ស្តែង(វេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការគាំទ្រផ្លូវចិត្ត និងសេដ្ឋកិច្ច សង្គម) ដោយមិនប្រកាន់ប្រភេទពិការភាព ភេទ អាយុ ជាតិសាសន៍ សាសនា ឬស្ថានភាពសេដ្ឋកិច្ចនោះឡើយ
- **<u>ការចូលរួម និងការធ្វើបរិយាបន្ន</u>** : ជនរងគ្រោះ និងអង្គការតំណាងគួរតែចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធនឹងគោលនយោបាយនិងកម្មវិធីផ្សេងៗ ដើម្បីធានាអោយមានបរិយាបន្នសេដ្ឋកិច្ច សង្គម ដល់ជនរងគ្រោះ
- **<u>ភាពងាយស្រួល</u>** : ជនរងគ្រោះ និងជនមានពិការភាព ត្រូវតែមានសិទ្ធិចូលប្រើប្រាស់សេវាកម្មដែលពួកគេត្រូវការដោយគ្មានឧបសគ្គ។ គ្រប់របាំងដែលរារាំងដល់ការទទួលបានសេវា ទាំងផ្នែករូបវន្ត ហិរញ្ញវត្ថុ ទីជីថល ភាសា ច្បាប់ ក៏ដូចជាកត្តាអាយុ យេនឌ័រ និងវប្បធម៌ ត្រូវតែត្រូវបានដោះស្រាយជាប្រព័ន្ធ រួមទាំងការផ្តល់នូវការស្នាក់នៅដែលសមរម្យផងដែរ
- **<u>ភាពងាយរងគ្រោះ</u>** : ការរៀបចំ និងការផ្តល់សេវាគាំទ្រ ត្រូវតែឆ្លើយតបទៅនឹងភាពងាយរងគ្រោះ ពហុវិមាត្ររបស់ជនរងគ្រោះ រួមមាន ការប៉ះពាល់កាយសម្បទាដោយសារការបាត់បង់អវយវៈ និងពិការភាពដែលទាមទារឧបករណ៍ជំនួយជាប្រចាំ ផលប៉ះពាល់ផ្លូវចិត្តដូចជាវិបត្តិបាក់ស្បាត និងជំងឺបាក់ទឹកចិត្ត ព្រមទាំងបន្ទុកសេដ្ឋកិច្ចពីការបាត់បង់ចំណូល និងប្រឈមនឹងបំណុល។
- **<u>អាយុ យេនឌ័រ ពិការភាព និង ការពិចារណាពីភាពចម្រុះ</u>** : រាល់ការរៀបចំផែនការនិងការចនាកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះ ត្រូវគិតគូរឱ្យបានហ្មត់ចត់ពីកត្តាអាយុ យេនឌ័រ ពិការភាព និងអត្តសញ្ញាណចម្រុះរបស់ជនរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបទពិសោធន៍ជាក់ស្តែងរបស់ពួកគេ។ ទន្ទឹមនឹងនេះ ការប្រមូលទិន្នន័យដែលបែងចែកតាមអាយុ ភេទ និងពិការភាព គឺជាកត្តាចាំបាច់ ដើម្បីធានាឱ្យការផ្តល់សេវាកម្មមានប្រសិទ្ធភាព និងចំគោលដៅ

- **<u>និរន្តរភាព និងភាពជាម្ចាស់ថ្នាក់ជាតិ</u>** : ដោយសារកិច្ចសង្គ្រោះជនរងគ្រោះគឺជាសកម្មភាពរយៈពេលវែង ការរៀបចំគោលនយោបាយ ផែនការសកម្មភាព និងផែនការហិរញ្ញវត្ថុ ត្រូវតែអនុវត្តឱ្យមានប្រសិទ្ធភាព និងចាក់គ្រឹះយ៉ាងរឹងមាំក្នុងកម្រិតថ្នាក់ជាតិ ដើម្បីធានាបាននូវនិរន្តរភាពយូរអង្វែង
- **<u>វិធីសាស្ត្រផ្អែកលើសិទ្ធិ</u>** : កិច្ចសង្គ្រោះជនរងគ្រោះត្រូវអនុវត្តស្របតាមច្បាប់មនុស្សធម៌ និងសិទ្ធិមនុស្សជាតិ អន្តរជាតិ ដើម្បីធានាឱ្យជនរងគ្រោះទទួលបានសិទ្ធិពេញលេញលើសេវាសុខភាព ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការអប់រំ ការងារ និងការគាំពារសង្គម។ ទន្ទឹមនឹងនេះ ការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធ និងភាពជាអ្នកដឹកនាំ គឺជាកត្តាចាំបាច់ដើម្បីសម្រេចបាននូវជោគជ័យក្នុងការអនុវត្តគោលការណ៍ណែនាំនេះ
- **<u>ការអនុវត្តផ្អែកលើភស្តុតាង</u>** : គឺជាការផ្តល់សេវាថែទាំតាមបែបសមាហរណកម្ម ដោយផ្អែកលើការសិក្សាស្រាវជ្រាវដ៏ល្អបំផុត ទិន្នន័យគ្លីនិកពីអ្នកជំនាញ និងតម្រូវការជាក់ស្តែងរបស់ជនរងគ្រោះ។ វិធីសាស្ត្រនេះមានគោលបំណងធានាឱ្យបាននូវសេវាកម្មប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីសម្រេចបាននូវលទ្ធផលល្អប្រសើរបំផុតសម្រាប់ជនរងគ្រោះ។

ជំពូកទី៣៖ សមាសធាតុនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

សមាសធាតុនៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ រួមមាន៖

ក. ការប្រមូលទិន្នន័យ
ខ. ការសង្គ្រោះបន្ទាន់ និងថែទាំវេជ្ជសាស្ត្របន្ត
គ. ការស្តារលទ្ធភាពពលកម្ម
ឃ. ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម
ង. បរិយាបន្នសេដ្ឋកិច្ច សង្គម
ច. ច្បាប់និងគោលនយោបាយ។

ក. ការប្រមូលទិន្នន័យ

ដំណើរការប្រមូល ធ្វើការវិភាគ និងចែករំលែកទិន្នន័យ គឺជាកត្តាសំខាន់ក្នុងការរៀបចំផែនការ និងតាមដានសកម្មភាពនៃកិច្ចសង្គ្រោះជនរងគ្រោះឱ្យមានប្រសិទ្ធភាព ដោយផ្អែកលើការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានច្បាស់លាស់តាមរយៈកម្រងសំណួរស្តង់ដាអន្តរជាតិ(ដូចជា Washington Group) ដែលបែងចែកតាមភេទ អាយុ និងប្រភេទពិការភាព។ ទន្ទឹមនឹងការប្រមូលទិន្នន័យជនមានពិការភាពក្នុងក្របខ័ណ្ឌជាតិ ការចងក្រងព័ត៌មានអំពីសេវាកម្មដែលមានស្រាប់ គឺជាជំហានដ៏សំខាន់ដើម្បីជួយសម្របសម្រួល និងបញ្ជូនជនរងគ្រោះ ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាល ឱ្យអាចជម្នះនូវឧបសគ្គនានាដូចជា បញ្ហាថវិកាធ្វើដំណើរ កង្វះព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធ និងការរើសអើង ដើម្បីទទួលបានសេវាថែទាំសុខភាព និងលើកកម្ពស់គុណភាពជីវិត។ ចំពោះកិច្ចការនេះទាមទារឱ្យមានកិច្ចសហការឱ្យបានជិតស្និទ្ធ និងមានស្តង់ដាច្បាស់លាស់ រវាងភាគីពាក់ព័ន្ធជាច្រើន រួមមានអាជ្ញាធរមីន អាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករសកម្មភាពមីនជាតិ អន្តរជាតិ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា អង្គការមិនមែនរដ្ឋាភិបាល

និងបណ្តាញអ្នកស្ម័គ្រចិត្តជនមានពិការភាព ដើម្បីជានាបាននូវការប្រមូលទិន្នន័យនៅទីវាលដែលមានលក្ខណៈត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ។

ខ. ការសង្គ្រោះបន្ទាន់ និងថែទាំវេជ្ជសាស្ត្របន្ត

ការសង្គ្រោះបន្ទាន់ និងថែទាំវេជ្ជសាស្ត្របន្ត គឺជាកិច្ចការដ៏មានសារៈសំខាន់បំផុត ដែលរួមមានសកម្មភាពគន្លឹះជាច្រើនដូចជា ការសង្គ្រោះបឋម ការជម្លៀសជនរងគ្រោះជាបន្ទាន់ ការគ្រប់គ្រងឈាម និងការផ្តល់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ រួមមានការវះកាត់ ការបញ្ចូលឈាម ការគ្រប់គ្រងការឈឺចាប់ និងសេវាសុខភាពជាទៃទៀត ដែលផ្តល់ដោយក្រុមគ្រូពេទ្យឯកទេសពហុជំនាញ រួមជាមួយមធ្យោបាយដឹកជញ្ជូនសង្គ្រោះបន្ទាន់ឱ្យបានទាន់ពេលវេលា។ ការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពទាំងនេះ ចាំបាច់ត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវ និងមានលក្ខណៈស្របគ្នាទាំងនៅក្នុងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីក្លាយជាផ្នែកមួយដ៏រឹងមាំនៃប្រព័ន្ធសុខាភិបាលរួមនៅកម្ពុជា។

គ. ការស្តារលទ្ធភាពពលកម្ម

យោងតាមនិយមន័យរបស់អង្គការសុខភាពពិភពលោក និងក្នាក់ងារប្រឹក្សាយោបល់ថ្នាក់តំបន់ ការស្តារលទ្ធភាពពលកម្ម គឺជាកិច្ចការងារអន្តរវិស័យដែលត្រូវបានរៀបចំឡើងដើម្បីពង្រឹងសុខុមាលភាព និងជួយសម្រួលដល់ការរស់នៅរបស់ជនមានពិការភាព ផ្អែកលើលក្ខខណ្ឌសុខភាពជាក់ស្តែងរបស់បុគ្គលម្នាក់ៗក្នុងគោលបំណងឱ្យពួកគេអាចវិលត្រឡប់ទៅរកជីវភាពរស់នៅជាធម្មតាវិញ។ ដំណើរការនេះមិនត្រឹមតែផ្តោតលើទិដ្ឋភាពសុខភាព និងការបម្លាស់ទីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគ្របដណ្តប់លើការគាំទ្រផ្នែកផ្លូវចិត្តនិងចិត្តសង្គម ហិរញ្ញវត្ថុ ការអប់រំ និងការធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម ដើម្បីឱ្យជនរងគ្រោះ គ្រួសារនិងសហគមន៍ អាចយល់ដឹងពីវិធីសាស្ត្រដោះស្រាយបញ្ហាប្រឈមក្នុងជីវភាពប្រចាំថ្ងៃ និងឆ្លើយតបទៅនឹងស្ថានភាពសុខភាពរបស់ពួកគាត់បានយ៉ាងប្រសើរ។

ក្នុងក្របខ័ណ្ឌវិស័យសង្គមកិច្ច ការស្តារលទ្ធភាពពលកម្មគឺជាសមាសភាគដ៏សំខាន់នៃកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលរួមមានការពិនិត្យវាយតម្លៃ ការព្យាបាលដោយចលនា ការផលិត ការបំពាក់អវយវៈសិប្បនិម្មិត គ្រឿងរណប រួមទាំងការហ្វឹកហ្វឺនប្រើប្រាស់ឧបករណ៍ជំនួយផ្សេងៗដូចជារទេះរុញជាដើម។ ដើម្បីជានាបាននូវគុណភាព និងប្រសិទ្ធភាពខ្ពស់បំផុត កិច្ចការនេះទាមទារឱ្យមានការសហការពីក្រុមគ្រូពេទ្យឯកទេសពហុជំនាញ រួមមាន វេជ្ជបណ្ឌិត អ្នកជំនាញផលិតអវយវៈសិប្បនិម្មិត គិលានុបដ្ឋាយិកា និងអ្នកជំនាញព្យាបាលដោយចលនា ដើម្បីជួយលុបបំបាត់ការឈឺចាប់ និងលើកកម្ពស់សមត្ថភាពរាងកាយ ផ្លូវចិត្ត និងសតិបញ្ញារបស់ជនរងគ្រោះឱ្យបានពេញលេញ។

ឃ. ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម

ការគាំទ្រផ្លូវចិត្តនិងចិត្តសង្គម គឺជាសមាសភាគស្នូលនៃកិច្ចសង្គ្រោះជនរងគ្រោះ ដែលត្រូវបានអនុវត្តតាមរយៈយន្តការពីរប្រភេទដូចខាងក្រោម៖

- **ប្រព័ន្ធផ្លូវការ** : ការផ្តល់សេវាព្យាបាលផ្លូវចិត្ត និងសតិបញ្ញាដោយក្រុមអ្នកជំនាញ រួមមាន វេជ្ជបណ្ឌិត អ្នកចិត្តសាស្ត្រ អ្នកប្រឹក្សាយោបល់ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត និងបុគ្គលិកសង្គមកិច្ច នៅតាមមន្ទីរពេទ្យមណ្ឌលសុខភាព និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម

- **ប្រព័ន្ធក្រៅផ្លូវការក្នុងសហគមន៍** : ការជ្រោមជ្រែងពីសមាជិកគ្រួសារ ចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ និងគ្រូបុរាណ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកទឹកចិត្តជនរងគ្រោះ។

បន្ថែមលើសេវាវេជ្ជសាស្ត្រ កិច្ចគាំពារនេះក៏ផ្តោតលើការបង្កើត បណ្តាញមិត្តអប់រំមិត្ត និងក្រុមគាំទ្រការងារសង្គម ដើម្បីឱ្យជនរងគ្រោះដែលមានស្ថានភាពប្រហាក់ប្រហែលគ្នាអាចចែករំលែកបទពិសោធន៍ និងលើកកម្ពស់សុខុមាលភាព ផ្លូវចិត្តឱ្យគ្នាទៅវិញទៅមក។ ទន្ទឹមនឹងនេះ ការរៀបចំវេទិកាសាធារណៈ សកម្មភាពវប្បធម៌ កីឡា និងការកម្សាន្តនានា ត្រូវបានជំរុញដើម្បីបង្កើនទំនាក់ទំនងក្នុងសហគមន៍ និងផ្តល់ឱកាសឱ្យជនរងគ្រោះមានសម្លេង ក៏ដូចជាការចូលរួម ក្នុងសង្គមដោយពេញលេញ។

១. បរិយាបន្នសេដ្ឋកិច្ច សង្គម

បរិយាបន្នសេដ្ឋកិច្ច សង្គម គឺជាកិច្ចការបង្កើនលទ្ធភាពដល់ជនរងគ្រោះក្នុងការទទួលបានការបណ្តុះបណ្តាល ការអប់រំ ការអភិវឌ្ឍជំនាញ កិច្ចគាំពារសង្គម និងឱកាសការងារស្មើៗគ្នា។ ក្នុងទិដ្ឋភាពបរិយាបន្នសេដ្ឋកិច្ច សង្គម ផ្តោត សំខាន់លើការពង្រឹងទំនាក់ទំនងគ្រួសារ និងសហគមន៍ ការបង្ការអំពើហិង្សាលើជនរងគ្រោះ និងការធានាឱ្យជនរងគ្រោះ មានសិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌ កីឡា និងការកម្សាន្តដោយមិនមានការរើសអើង។ ចំណែកឯបរិយាបន្នសេដ្ឋកិច្ច សង្គម ត្រូវបានជំរុញតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ការងារ ការផ្តល់ឥណទានខ្នាតតូច ការបង្កើត ប្រាក់ចំណូល និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍ រួមទាំងការជួយសម្រួលដល់ការសាងសង់ជម្រកសមរម្យ សម្រាប់ជនរងគ្រោះផងដែរ។

ជាចំណុចស្នូល ការអប់រំប្រកបដោយបរិយាបន្ន គឺជាសិទ្ធិមូលដ្ឋានដែលបើកផ្លូវឱ្យជនរងគ្រោះ និងជនងាយ រងគ្រោះទទួលបានចំណេះដឹង ចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា ព្រមទាំងការអប់រំក្រៅប្រព័ន្ធ និងការ រៀនសូត្រពេញមួយជីវិត។ ការទទួលបានការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសត្រឹមត្រូវ គឺជាគ្រឹះដ៏សំខាន់ដែល ជួយឱ្យជនរងគ្រោះអាចឈានទៅទទួលបានសិទ្ធិផ្សេងៗទៀត ដូចជាការថែទាំសុខភាព ការងារសមរម្យ និងការចូលរួម ក្នុងសកម្មភាពនយោបាយ ដែលទាមទារឱ្យមានការគាំទ្រ និងការចូលរួមពីគ្រប់កម្រិតនៃវិស័យសកម្មភាពមីន។

២. ច្បាប់ និងគោលនយោបាយ

ការរៀបចំកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចាំបាច់ត្រូវអនុវត្តឱ្យស្របតាមក្របខ័ណ្ឌ ច្បាប់ និងគោលនយោបាយជាតិ ដើម្បីធានាថាជនរងគ្រោះទទួលបានសិទ្ធិនិងឱកាសស្មើគ្នាក្នុងសង្គម រួមមាន សេវា សុខាភិបាល ការអប់រំ ការងារ និងកិច្ចគាំពារសង្គម។ រាល់សកម្មភាពទាំងអស់ត្រូវប្រកាន់ខ្ជាប់តាមស្តង់ដាសកម្មភាព កំចាត់មីនកម្ពុជា និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលគ្របដណ្តប់លើសុវត្ថិភាពការងារ ការការពារបរិស្ថាន និង ជាពិសេសគឺច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយត្រូវបានគ្របដណ្តប់លើផ្នែកសំខាន់ៗមួយចំនួនដូចជា៖

- ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- គោលនយោបាយជាតិស្តីពីសកម្មភាពមីន
- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- អនុសញ្ញាអូតាវ៉ា

- អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្ម តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន
- អនុក្រឹត្យស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនមានពិការភាពចូលបម្រើការងារ
- អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម
- បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

ជំពូកទី៤៖ វិធីសាស្ត្រពហុវិស័យ (កិច្ចសហការរួមគ្នា)

ក្នុងការឆ្លើយតប និងផ្តល់កិច្ចអន្តរាគមន៍ជូនជនរងគ្រោះឱ្យមានប្រសិទ្ធភាពខ្ពស់ យន្តការការងារត្រូវផ្តោតលើវិធីសាស្ត្រពហុវិស័យ តាមរយៈកិច្ចសហការជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ លើវិស័យសំខាន់ៗដូចខាងក្រោម៖

- **ការថែទាំ ជារួម តម្រឹមជាមួយគោលនយោបាយរបស់សុខាភិបាល** : គឺជាការបញ្ចូលសេវាសង្គ្រោះជនរងគ្រោះទៅក្នុងប្រព័ន្ធសុខាភិបាលជាតិដើម្បីធានាថាជនរងគ្រោះទទួលបានការថែទាំជាប្រព័ន្ធ ស្របតាមស្តង់ដា និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល
- **សេវាថែទាំសុខភាពនិងវេជ្ជសាស្ត្រ** : សំដៅលើការផ្តល់សេវាវេជ្ជសាស្ត្រគ្រប់ជ្រុងជ្រោយ រួមមានការសង្គ្រោះបន្ទាន់ ការវះកាត់ ការព្យាបាលជំងឺទូទៅ និងការថែទាំសុខភាពបន្តបន្ទាប់ ដើម្បីសង្គ្រោះជីវិត និងកាត់បន្ថយផលវិបាកនៃរបួសស្នាម
- **ការស្តារលទ្ធភាពពលកម្ម** : គឺជាដំណើរការជួយឱ្យជនរងគ្រោះទទួលបានមកវិញនូវសមត្ថភាពរាងកាយ និងមុខងារសរីរាង្គ តាមរយៈការព្យាបាលដោយចលនា និងការបំពាក់ឧបករណ៍ជំនួយ(ដូចជាអវយវៈសិប្បនិម្មិត ឬគ្រឿងរណប) ដើម្បីឱ្យពួកគាត់អាចរស់នៅដោយឯករាជ្យ
- **ការគាំទ្រផ្លូវចិត្ត** : គឺជាការផ្តល់សេវាប្រឹក្សាយោបល់ និងការព្យាបាលផ្លូវចិត្ត ដើម្បីជួយជនរងគ្រោះឱ្យជម្នះបាននូវបិត្តិស្មារតី ការតក់ស្លុត និងបង្កើនភាពរឹងមាំផ្នែកអារម្មណ៍សម្រាប់បន្តជីវិតទៅមុខ
- **បរិយាបន្នសេដ្ឋកិច្ច សង្គម** : គឺជាការបង្កលក្ខណៈងាយស្រួល និងលុបបំបាត់រាល់របាំងរារាំង ដើម្បីឱ្យជនរងគ្រោះអាចចូលរួមក្នុងសកម្មភាពសង្គម វប្បធម៌ និងសេដ្ឋកិច្ចឱ្យបានពេញលេញ និងមានសិទ្ធិស្មើៗគ្នាជាមួយអ្នកដទៃ
- **ការអប់រំ** : គឺជាការធានាឱ្យជនរងគ្រោះ និងកុមារមានពិការភាពទទួលបានការអប់រំគ្រប់កម្រិត(ក្នុង និងក្រៅប្រព័ន្ធ) ដោយគ្មានការរើសអើង ដើម្បីជាទុនចំណេះដឹងសម្រាប់កសាងអនាគត
- **ការប្រគល់អំណាច** : គឺជាការលើកកម្ពស់សមត្ថភាព និងទំនុកចិត្តលើខ្លួនឯងរបស់ជនរងគ្រោះ ដើម្បីឱ្យពួកគាត់មានលទ្ធភាពតស៊ូមតិ សម្រេចចិត្ត និងដឹកនាំជីវិតដោយខ្លួនឯង ក៏ដូចជាចូលរួមដឹកនាំក្នុងសហគមន៍
- **ការបណ្តុះបណ្តាលវិជ្ជាជីវៈ** : គឺជាការបង្រៀនជំនាញបច្ចេកទេស ឬវិជ្ជាជីវៈខ្លីៗ ដែលស្របតាមលក្ខណៈសម្បត្តិរូបរាងកាយ និងតម្រូវការទីផ្សារ ដើម្បីឱ្យជនរងគ្រោះមានសមត្ថភាពប្រកបរបរចិញ្ចឹមជីវិត
- **ការងារ** : សំដៅលើការបង្កឱកាសឱ្យជនរងគ្រោះទទួលបានការងារធ្វើ ទាំងក្នុងវិស័យរដ្ឋ ឯកជន ឬការប្រកបរបរស្វ័យនិយោជន៍ ដើម្បីជានាបាននូវចំណូល និងស្ថិរភាពសេដ្ឋកិច្ចគ្រួសារ

- **ប្រព័ន្ធគាំពារសង្គម(ជំនួយសង្គម និងសន្តិសុខសង្គម)** : គឺជាយន្តការដ្ឋក្នុងការផ្តល់សេវាគាំទ្រផ្នែកហិរញ្ញវត្ថុ ឬសម្ភារដល់ជនរងគ្រោះក្រីក្រ(ជំនួយសង្គម) និងការធានារ៉ាប់រងសុខភាព ឬប្រាក់សោធននិវត្តន៍ (សន្តិសុខសង្គម)
- **ជំនួយផ្នែកច្បាប់** : គឺជាការផ្តល់ព័ត៌មាន ការប្រឹក្សាយោបល់ ឬការជួយការពារតាមផ្លូវច្បាប់ ដើម្បីធានាថាជនរងគ្រោះមិនត្រូវបានរំលោភបំពានសិទ្ធិ និងទទួលបានយុត្តិធម៌សង្គម
- **ការបណ្តុះបណ្តាលជំនាញសង្គ្រោះបឋម និងព្យាបាលដោយកញ្ចាក់** : គឺជាការបណ្តុះបណ្តាលបច្ចេកទេសសង្គ្រោះជីវិតបឋមក្នុងសហគមន៍ និងការប្រើប្រាស់វិធីសាស្ត្រព្យាបាលដោយកញ្ចាក់ ដើម្បីកាត់បន្ថយការឈឺចាប់ផ្នែកសរីរាង្គ(ដូចជាការឈឺចាប់លើអវយវៈដែលបានកាត់រួច)។

ជំពូកទី៥៖ ការសម្របសម្រួល កិច្ចសហការ និងការអនុវត្ត

➢ តួនាទីរបស់អាជ្ញាធរមីន

អាជ្ញាធរមីន គឺជាស្ថាប័នបង្គោលក្នុងការសម្របសម្រួល និងជំរុញកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដ្ឋ អង្គការសង្គមស៊ីវិល និងដៃគូអន្តរជាតិ ដើម្បីធានាឱ្យមានវិធីសាស្ត្ររួមគ្នាប្រកបដោយប្រសិទ្ធភាព ក្នុងការអនុវត្តគោលការណ៍ណែនាំ និងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន។ ក្នុងតួនាទីជាអ្នកដឹកនាំ អាជ្ញាធរមីនបានផ្តល់ការណែនាំបច្ចេកទេស និងគាំទ្រដល់ការរៀបចំផែនការ និងសម្របសម្រួលក្នុងផ្តល់សេវាសំខាន់ៗ ចាប់តាំងពីការសង្គ្រោះបន្ទាន់ ការថែទាំវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្ម រហូតដល់ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម និងការជំរុញធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម។

ទន្ទឹមនឹងនេះ អាជ្ញាធរមីនមានការកិច្ចយ៉ាងសកម្មក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តស្តង់ដានីតិវិធីប្រតិបត្តិការ ដើម្បីធានាឱ្យស្របតាមការប្តេជ្ញាចិត្តថ្នាក់ជាតិ និងអន្តរជាតិ សំដៅកែលម្អគុណភាព និងលទ្ធភាពទទួលបានសេវាកម្មឱ្យកាន់តែទូលំទូលាយ។ បន្ថែមលើនេះ ស្ថាប័នក៏បានផ្តោតលើការងារបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់ដៃគូពាក់ព័ន្ធក្នុងវិស័យពិការភាព ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងផ្លែផ្កាជីវៈ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ គឺដើម្បីពង្រឹងក្របខ័ណ្ឌនៃកិច្ចសង្គ្រោះឱ្យកាន់តែរឹងមាំ និងធានាថារាល់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ព្រមទាំងជនមានពិការភាពទូទៅ នឹងទទួលបានការគាំទ្រគ្រប់ជ្រុងជ្រោយប្រកបដោយនិរន្តរភាពយូរអង្វែង។

➢ តួនាទីរបស់ស្ថាប័នរដ្ឋាភិបាល

ស្ថាប័នរដ្ឋាភិបាលដើរតួនាទីជាអ្នកដឹកនាំ និងតម្រង់ទិសគោលនយោបាយយ៉ាងសំខាន់ ក្នុងការគាំទ្រដល់អ្នកផ្តល់សេវាឱ្យចូលរួមធ្វើការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះប្រកបដោយប្រសិទ្ធភាព។ តាមរយៈការផ្តល់ការណែនាំបច្ចេកទេស ការបែងចែកធនធាន និងការធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងមូលដ្ឋានសុខាភិបាល ស្ថាប័នរដ្ឋដើម្បីធានាថារាល់សកម្មភាពជួយសង្គ្រោះទាំងអស់ត្រូវបានអនុវត្តស្របតាមការប្តេជ្ញាចិត្តជាតិ និងអន្តរជាតិ។

ក្នុងនោះ ស្ថាប័នរដ្ឋាភិបាលបានផ្តោតលើការងារគន្លឹះសំខាន់ៗ រួមមានការកសាងសមត្ថភាពតាមរយៈការពង្រឹងជំនាញ និងចំណេះដឹងដល់អ្នកផ្តល់សេវា ដើម្បីធានាបាននូវគុណភាពនៃការថែទាំវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្ម ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម និងបរិយាបន្នសេដ្ឋកិច្ច សង្គម។ ទន្ទឹមនឹងនេះ ការងារត្រួតពិនិត្យ និងវាយតម្លៃ ក៏ត្រូវបាន

អនុវត្តយ៉ាងសកម្មដើម្បីតាមដានវឌ្ឍនភាព និងផ្តល់អនុសាសន៍ជាយុទ្ធសាស្ត្រក្នុងការកែលម្អសេវាកម្ម ព្រមទាំងជានានូវនិរន្តរភាពយូរអង្វែង សំដៅលើកកម្ពស់សិទ្ធិ សុខុមាលភាព និងបរិយាបន្នសម្រាប់ជនមានពិការភាពគ្រប់រូបនៅកម្ពុជា។

➢ តួនាទីប្រតិបត្តិការសកម្មភាពមីន

ប្រតិបត្តិការសកម្មភាពមីនដើរតួនាទីជាអ្នកអនុវត្តផ្ទាល់នូវកម្មវិធីជំនួយនានា ដើម្បីគាំទ្រដល់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងជនមានពិការភាព ស្របតាមគោលការណ៍ណែនាំថ្នាក់ជាតិ និងអន្តរជាតិ។ ភារកិច្ចរបស់ពួកគេគឺការរៀបចំស្តង់ដានីតិវិធីប្រតិបត្តិការ និងផែនការសកម្មភាពដែលផ្តែកលើសសរស្តម្ភសំខាន់ៗចំនួន៦ រួមមាន ការសង្គ្រោះបន្ទាន់និងថែទាំវេជ្ជសាស្ត្របន្ត ការស្តារលទ្ធភាពពលកម្ម ការគាំទ្រផ្លូវចិត្តនិងចិត្តសង្គម បរិយាបន្នសេដ្ឋកិច្ច សង្គម ការអនុវត្តច្បាប់និងគោលនយោបាយ និងការគ្រប់គ្រងទិន្នន័យ។

ក្រៅពីការងារបច្ចេកទេស ប្រតិបត្តិការសកម្មភាពមីនក៏មានទំនួលខុសត្រូវក្នុងការកៀរគរធនធានពីប្រភពជាតិ និងអន្តរជាតិ ដើម្បីធានានិរន្តរភាព និងពង្រីកវិសាលភាពនៃកិច្ចសង្គ្រោះជនរងគ្រោះ តាមរយៈការផ្តល់សេវាវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្មកាយសម្បទា និងការបង្កើតឱកាសចិញ្ចឹមជីវិត។ ប្រតិបត្តិការទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពជីវិត សេចក្តីថ្លៃថ្នូរ និងការធ្វើសមាហរណកម្មជនរងគ្រោះឱ្យរស់នៅក្នុងសង្គមប្រកបដោយបរិយាបន្ន។

➢ តួនាទីអង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល

អង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ដើរតួនាទីជាស្ពានចម្លងដ៏សំខាន់រវាងគោលនយោបាយរដ្ឋាភិបាល និងតម្រូវការជាក់ស្តែងរបស់ជនរងគ្រោះ ដើម្បីធានាឱ្យការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះប្រកបដោយបរិយាបន្ន។ ក្នុងនាមជាអ្នកតស៊ូមតិ និងអ្នកផ្តល់សេវា អង្គការទាំងនេះបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់សិទ្ធិអំណាចដល់ជនរងគ្រោះ ដើម្បីឱ្យពួកគាត់មានសម្លេងក្នុងដំណើរការសម្រេចចិត្ត ព្រមទាំងផ្តល់សេវាចាំបាច់នានាដូចជា ការថែទាំសុខភាព ការស្តារលទ្ធភាពពលកម្ម ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

លើសពីនេះ អង្គការជនពិការក៏មានការកិច្ចគន្លឹះក្នុងទិដ្ឋភាពយុទ្ធសាស្ត្រ ដោយផ្តោតលើការស្រាវជ្រាវ និងការប្រមូលទិន្នន័យជាក់ស្តែង ដើម្បីជួយឱ្យការរៀបចំកម្មវិធីជំនួយចំគោលដៅ និងឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទទួលផល។ ទន្ទឹមនឹងនេះ ការកៀរគរធនធានតាមរយៈការបង្កើនការយល់ដឹង និងការកសាងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ក៏ត្រូវបានអនុវត្តយ៉ាងសកម្ម ដើម្បីធានានិរន្តរភាពនៃកម្មវិធីកិច្ចសង្គ្រោះជនរងគ្រោះ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ សុទ្ធតែមានគោលដៅរួមក្នុងការលើកកម្ពស់សិទ្ធិ សមធម៌ និងឱកាសស្មើគ្នា ដែលនាំទៅដល់ការបង្កើនគុណភាពជីវិត និងសេចក្តីថ្លៃថ្នូររបស់ជនមានពិការភាពគ្រប់រូបក្នុងសង្គម។

➢ យន្តការសហប្រតិបត្តិការអន្តរជាតិ និងការផ្តល់មូលនិធិសម្រាប់ជួយដល់ជនរងគ្រោះ

យន្តការសហប្រតិបត្តិការអន្តរជាតិ និងការកៀរគរមូលនិធិ គឺជាកត្តាគន្លឹះក្នុងការធានាបាននូវប្រសិទ្ធភាព និងនិរន្តរភាពសម្រាប់កម្មវិធីជំនួយដល់ជនរងគ្រោះ និងជនមានពិការភាពនៅកម្ពុជា។ តាមរយៈភាពជាដៃគូទ្វេភាគី និងពហុភាគីជាមួយម្ចាស់ជំនួយអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល កម្ពុជាអាច

ប្រមូលបាននូវធនធានហិរញ្ញវត្ថុ និងបច្ចេកទេសយ៉ាងទូលំទូលាយពីប្រភពចម្រុះ រួមមានជំនួយមនុស្សធម៌ កម្មវិធីជំនួយអភិវឌ្ឍន៍ មូលនិធិទំនុកចិត្ត និងការរួមចំណែកពីវិស័យឯកជន ដើម្បីគាំទ្រដល់សេវាសុខាភិបាល ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការគាំទ្រផ្លូវចិត្ត និងចិត្តសង្គម និងបរិយាបន្នសេដ្ឋកិច្ច សង្គម។

ទន្ទឹមនឹងនេះ កិច្ចសហប្រតិបត្តិការនេះបានផ្តល់ឱកាសដល់ការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹងតាមរយៈការផ្លាស់ប្តូរបទពិសោធន៍ល្អៗ និងការពង្រឹងវិជ្ជាជីវៈមន្ត្រីជំនាញឱ្យកាន់តែប្រសើរឡើង។ លើសពីនេះ យន្តការមូលនិធិទំនុកចិត្ត និងកិច្ចព្រមព្រៀងអន្តរជាតិ គឺជាគ្រឹះយ៉ាងសំខាន់ក្នុងការធានានិរន្តរភាពយូរអង្វែង ដើម្បីឱ្យកិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះមានស្ថិរភាព និងអាចឈានទៅសម្រេចបាននូវការកសាងសង្គមបរិយាបន្ន ព្រមទាំងលើកកម្ពស់គុណភាពជីវិតរបស់ជនរងគ្រោះគ្រប់រូបប្រកបដោយសេចក្តីថ្លៃថ្នូរ។

➢ ទីភ្នាក់ងារអង្គការសហប្រជាជាតិ

ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើរតួនាទីជាដៃគូយុទ្ធសាស្ត្រក្នុងការគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ កិច្ចសហប្រតិបត្តិការនេះធានាថាជនរងគ្រោះ និងជនមានពិការភាពគ្រប់ប្រភេទទទួលបានការគាំទ្រគ្រប់ជ្រុងជ្រោយ និងមាននិរន្តរភាព តាមរយៈការផ្តល់ជំនាញបច្ចេកទេស ការណែនាំគោលនយោបាយ ហិរញ្ញប្បទាន និងការគាំទ្រដល់ការអនុវត្តកម្មវិធីផ្ទាល់ រួមមាន៖

- **កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ** : ផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍគោលនយោបាយ និងការកៀរគរធនធាន ដើម្បីធានាថាវិស័យសកម្មភាពមីនត្រូវបានបញ្ចូលទៅក្នុងអាទិភាពនៃផែនការអភិវឌ្ឍន៍ជាតិ
- **មូលនិធិកុមារអង្គការសហប្រជាជាតិ** : ផ្តល់អាទិភាពលើកុមាររងគ្រោះ ដោយលើកកម្ពស់សិទ្ធិទទួលបានការអប់រំ បរិយាបន្នសង្គម ការថែទាំសុខភាព និងការគាំទ្រផ្លូវចិត្ត
- **អង្គការសុខភាពពិភពលោក** : ជួយគាំទ្រដល់ការកែលម្អប្រព័ន្ធសេវាថែទាំសុខភាព ការស្តារលទ្ធភាពពលកម្ម និងការផ្តល់ជំនួយសុខភាពផ្លូវចិត្តឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព
- **អង្គការពលកម្មអន្តរជាតិ** : ជំរុញបរិយាបន្នសេដ្ឋកិច្ច តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបង្កើនឱកាសការងារ ដើម្បីជួយឱ្យជនរងគ្រោះអាចសម្រេចបាននូវឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ
- **ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស** : លើកកម្ពស់ការគោរពសិទ្ធិជនមានពិការភាព ដោយធានាថារាល់កម្មវិធីជំនួយត្រូវបានអនុវត្តស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។

ជំពូកទី៦៖ ក្របខ័ណ្ឌច្បាប់សម្រាប់កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ គឺជាសសរស្តម្ភដ៏រឹងមាំ និងជាមូលដ្ឋានគ្រឹះមិនអាចខ្វះបាន ក្នុងការកំណត់នូវសិទ្ធិ កាតព្វកិច្ច និងបទដ្ឋាននៃសេវាគាំពារដល់ជនរងគ្រោះ។ ការផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួតរវាង ច្បាប់អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តជាតិ បានបង្កើតនូវយន្តការការពារផ្លូវច្បាប់ដ៏មានប្រសិទ្ធភាព ដើម្បីធានាបាននូវសេចក្តីថ្លៃថ្នូរ និងបរិយាបន្នពិតប្រាកដសម្រាប់ជនរងគ្រោះគ្រប់រូប។

៦.១. ក្របខ័ណ្ឌ និងអនុសញ្ញាអន្តរជាតិសម្រាប់កិច្ចសង្គ្រោះជនរងគ្រោះ

- **អនុសញ្ញាអូតាវ៉ា** : គឺមានគោលបំណងដើម្បីបញ្ចប់ការរងគ្រោះ និងការបាត់បង់ជីវិតដែលបង្កឡើងដោយគ្រាប់មីនប្រឆាំងមនុស្ស តាមរយៈការហាមឃាត់ជាច់ខាតលើការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីន ព្រមទាំងកំណត់ជាកាតព្វកិច្ចអន្តរជាតិក្នុងការបោសសម្អាតផ្ទៃដីដែលមានមីន និងការផ្តល់ **«កិច្ចសង្គ្រោះជនរងគ្រោះ»** ជាផ្នែកមួយដ៏សំខាន់មិនអាចខ្វះបាន ដើម្បីជានាឱ្យពួកគេទទួលបានការគាំទ្រ និងការលើកកម្ពស់សិទ្ធិឡើងវិញក្នុងសង្គម

- **អនុសញ្ញាស្តីពីគ្រាប់បែកចង្កោម** : គឺមានគោលបំណងដើម្បីលុបបំបាត់គ្រោះថ្នាក់ដែលបង្កឡើងដោយគ្រាប់បែកចង្កោម តាមរយៈការហាមឃាត់ជាច់ខាតលើការប្រើប្រាស់ ការផលិត ការផ្ទេរ និងការរក្សាទុក ព្រមទាំងកំណត់កាតព្វកិច្ចឱ្យកាន់តែជាក់លាក់ក្នុងការបោសសម្អាតសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះទាំងនោះ និងការផ្តល់ជំនួយដ៏ទូលំទូលាយដល់ជនរងគ្រោះ រួមមាន ការស្តារលទ្ធភាពពលកម្ម ការគាំទ្រផ្លូវចិត្តនិងចិត្តសង្គម និងការធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម ដើម្បីជានាឱ្យពួកគេទទួលបានសិទ្ធិនិងឱកាសពេញលេញក្នុងសង្គម

- **អនុសញ្ញាស្តីពីសិទ្ធិជនពិការ** : គឺមានគោលបំណងដើម្បីលើកកម្ពស់ កិច្ចការពារ និងធានាឱ្យបាននូវការអនុវត្តពេញលេញ និងស្មើភាពគ្នានូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ដោយជនមានពិការភាពគ្រប់រូបព្រមទាំងជំរុញការគោរពចំពោះសេចក្តីថ្លៃថ្នូរដែលមានពីកំណើតរបស់ពួកគេ តាមរយៈការលុបបំបាត់រាល់ទម្រង់នៃឧបសគ្គ និងការរើសអើង ដើម្បីឱ្យពួកគេអាចចូលរួមយ៉ាងសកម្ម និងពេញលេញក្នុងជីវភាពសង្គមជាតិ

- **ផែនការសកម្មភាពសៀមរាប អង្គរ(២០២៥-២០២៩)** : គឺមានគោលបំណងដើម្បីកំណត់នូវផែនទីបង្ហាញផ្លូវ និងសកម្មភាពជាក់ស្តែងសម្រាប់រដ្ឋភាគីនៃអនុសញ្ញាអូតាវ៉ា ក្នុងការបង្កើនល្បឿនបោសសម្អាតមីនឱ្យអស់ពីផ្ទៃដីដែលបានកំណត់ ការពង្រឹងការអប់រំកាត់បន្ថយគ្រោះថ្នាក់ និងការជំរុញកិច្ចសង្គ្រោះជនរងគ្រោះឱ្យមានលក្ខណៈជាប្រព័ន្ធ បរិយាបន្ន និងនិរន្តរភាព សំដៅសម្រេចឱ្យបាននូវចក្ខុវិស័យពិភពលោកមួយដែលគ្មានមីន និងគ្មានជនរងគ្រោះថ្មី

- **គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព** : គឺមានគោលបំណងដើម្បីលុបបំបាត់ភាពក្រីក្រ ការពារភពផែនដី និងធានាឱ្យមានសន្តិភាព និងវិបុលភាពសម្រាប់មនុស្សគ្រប់រូបនៅទូទាំងសកលលោក តាមរយៈការជំរុញការអភិវឌ្ឍដែលប្រកបដោយបរិយាបន្ន និងសមធម៌ ដោយឈរលើគោលការណ៍គ្រឹះ «មិនបោះបង់នរណាម្នាក់» ជាពិសេសជនមានពិការភាព និងក្រុមជនងាយរងគ្រោះបំផុត

- **យុទ្ធសាស្ត្រអ៊ីឈាន់(Incheon Strategy)** : គឺមានគោលបំណងដើម្បីពន្លឿនការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកតាមរយៈការកំណត់នូវគោលដៅជាក់លាក់ចំនួន១០ ដែលអាចវាស់វែងបាន សំដៅកាត់បន្ថយភាពក្រីក្រ ជំរុញការចូលរួមក្នុងកិច្ចការនយោបាយ និងការសម្រេចចិត្ត ព្រមទាំងបង្កើនលក្ខណៈងាយស្រួលក្នុងបរិស្ថានរូបវន្ត និងព័ត៌មានវិទ្យាសម្រាប់ជនមានពិការភាពគ្រប់រូប

- **ស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ IMAS13.10** : គឺមានគោលបំណងដើម្បីផ្តល់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងការណែនាំបច្ចេកទេសដល់ប្រតិបត្តិករសកម្មភាពមីន ក្នុងការគាំទ្រដល់កិច្ចសង្គ្រោះជនរងគ្រោះ តាមរយៈការប្រមូល

និងគ្រប់គ្រងទិន្នន័យឱ្យបានត្រឹមត្រូវ ច្បាស់លាស់ ការផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ និងការជួយសម្របសម្រួលឱ្យជនរងគ្រោះអាចទទួលបានសេវាគាំពារពហុវិស័យប្រកបដោយបរិយាបន្ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរយៈពេលវែងរបស់ពួកគេ។

៦.២. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិសម្រាប់កិច្ចសង្គ្រោះជនរងគ្រោះ

▪ **ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ** : គឺមានគោលបំណងដើម្បីធានាឱ្យជនមានពិការភាពទទួលបាននូវសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូរពេញលេញ តាមរយៈការកំណត់នូវវិធានការច្បាប់សម្រាប់បង្ការ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើង ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ពួកគេក្នុងការទទួលបានសេវាសាធារណៈ ការអប់រំ សុខាភិបាល និងការងារ សំដៅជំរុញឱ្យមានការចូលរួមដោយស្មើភាពនិងសកម្មនៅក្នុងកិច្ចអភិវឌ្ឍន៍សង្គមជាតិ

▪ **គោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥** : គឺមានគោលបំណងដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ «ប្រទេសកម្ពុជារួចផុតពីផលប៉ះពាល់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ ធ្វើឱ្យដីវាលរស់នៅប្រកបដោយចីរភាព ជំរុញសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ» តាមរយៈការបញ្ចប់ការបោសសម្អាតមីន និងសំណល់យុទ្ធភណ្ឌសល់ពីសង្គ្រាមឱ្យអស់ពីផ្ទៃដីដែលបានកំណត់ព្រមទាំងពង្រឹងយន្តការសង្គ្រោះជនរងគ្រោះឱ្យមាននិរន្តរភាព និងបរិយាបន្ន ដោយធ្វើសមាហរណកម្មសេវាគាំទ្រទាំងផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្មកាយសម្បទា បរិយាបន្នសេដ្ឋកិច្ច សង្គម ទៅក្នុងប្រព័ន្ធជាតិជារួមសំដៅធានាឱ្យបាននូវសុវត្ថិភាព និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ឱ្យបានយូរអង្វែង

▪ **ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨** : គឺមានគោលបំណងដើម្បីលើកកម្ពស់គុណភាពជីវិត សេចក្តីថ្លៃថ្នូរ និងការចូលរួមរបស់ជនមានពិការភាពក្នុងគ្រប់សកម្មភាពសង្គម តាមរយៈការបញ្ជ្រាបបរិយាបន្នពិការភាពទៅក្នុងគោលនយោបាយ និងសេវាសាធារណៈគ្រប់វិស័យ ការពង្រឹងសេវាសុខាភិបាល និងការស្តារលទ្ធភាពពលកម្មសម្បទាឱ្យកាន់តែមានប្រសិទ្ធភាព និងការបង្កើនឱកាសសេដ្ឋកិច្ចតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ សំដៅកាត់បន្ថយភាពក្រីក្រ និងធានាឱ្យមានសមធម៌សម្រាប់ជនមានពិការភាពគ្រប់រូបនៅក្នុងសង្គម

▪ **គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ** : គឺមានគោលបំណងដើម្បីផ្តល់នូវក្របខ័ណ្ឌបច្ចេកទេស និងស្តង់ដាប្រតិបត្តិការួមសម្រាប់សម្របសម្រួលសេវាពហុវិស័យឱ្យមានគុណភាព និងប្រសិទ្ធភាព ក្នុងគោលដៅធានាឱ្យជនរងគ្រោះទទួលបាននូវការសង្គ្រោះបន្ទាន់ ការថែទាំវេជ្ជសាស្ត្រ ការព្យាបាលការស្តារលទ្ធភាពពលកម្មកាយសម្បទា និងការគាំទ្រផ្នែកសេដ្ឋកិច្ច សង្គម ដើម្បីឱ្យពួកគេអាចរស់នៅក្នុងសង្គមដោយសេចក្តីថ្លៃថ្នូរ និងមានគុណភាពជីវិតប្រសើរឡើង

▪ **ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាជំពូកទី២៣** : គឺមានបំណងដើម្បីកំណត់នូវបទដ្ឋានបច្ចេកទេស និងនីតិវិធីប្រតិបត្តិការស្តង់ដា សម្រាប់តម្រង់ទិសដល់ប្រតិបត្តិករទាំងអស់ ក្នុងការផ្តល់សេវាគាំពារជនរងគ្រោះឱ្យមានសច្ចភាព និងគុណភាពខ្ពស់បំផុត តាមរយៈការគ្រប់គ្រងទិន្នន័យឱ្យបានច្បាស់លាស់ និង ការសម្របសម្រួលសេវា

ពហុវិស័យទាំងផ្នែកវេជ្ជសាស្ត្រ ផ្លូវចិត្តនិងចិត្តសង្គម និងសេដ្ឋកិច្ច សង្គម ដើម្បីធានាថាជំនួយត្រូវបានផ្តល់ចំគោលដៅ និងឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ជនរងគ្រោះ

- **គោលការណ៍ណែនាំមធ្យោបាយថ្នាក់ជាតិ** : គឺមានគោលបំណងដើម្បីជំរុញការកសាង «បរិស្ថានគ្មានរបាំង» តាមរយៈការអនុវត្តស្តង់ដារចនាជាសកល នៅក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសំណង់អគារសាធារណៈ សំដៅធានាឱ្យជនមានពិការភាព និងជនរងគ្រោះអាចចល័តទីបានដោយសុវត្ថិភាព មានឯករាជ្យភាព និងអាចទទួលបានសេវាសង្គមនានាដោយសមធម៌។

ជំពូកទី៧៖ បញ្ហាប្រឈម ទិសដៅបន្ត និងអនុសាសន៍

៧.១. បញ្ហាប្រឈម

បញ្ហាប្រឈមក្នុងកិច្ចសង្គ្រោះជនរងគ្រោះមិនត្រឹមតែស្ថិតលើកត្តាថវិកាប៉ុណ្ណោះទេប៉ុន្តែគឺជា «បញ្ហាប្រព័ន្ធ» ដែលទាមទារឱ្យមានការដោះស្រាយស៊ីជម្រៅលើសសរស្តម្ភសំខាន់ៗដូចខាងក្រោម៖

- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈភាគច្រើន រួមមាន សាលារៀន មន្ទីរពេទ្យ និងទីកន្លែងការងារ នៅមិនទាន់អនុវត្តតាមស្តង់ដា «រចនាជាសកល» នៅឡើយ។ កង្វះខាតនេះបានបង្កើតនូវ «ពិការភាពទីពីរ» សម្រាប់ជនរងគ្រោះ ដែលជាពិការភាពបង្កឡើងដោយបរិស្ថានជុំវិញមិនអំណោយផល រារាំងដល់ការធ្វើចលនា និងការចូលរួមក្នុងសង្គមដោយឯករាជ្យ
- បច្ចុប្បន្នការផ្គត់ផ្គង់ឧបករណ៍ជំនួយបច្ចេកទេស រួមមាន រទេះរុញ ឈើច្រត់ អវយវៈសិប្បនិម្មិត និងគ្រឿងណេប នៅមិនទាន់ឆ្លើយតបបានពេញលេញទៅនឹងតម្រូវការជាក់ស្តែងទាំងបរិមាណ និងគុណភាពនៅឡើយ។ ជនរងគ្រោះជាច្រើននៅតំបន់ដាច់ស្រយាលជួបការលំបាកយ៉ាងខ្លាំង ក្នុងការទទួលបានឧបករណ៍ដែលស័ក្តិសមនឹងសណ្ឋានដីរស់នៅ និងស្ថានភាពពិការភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា និងសេវាសុខាភិបាលឯកទេស នៅមានវិសាលភាពគ្របដណ្តប់មានកម្រិត ដែលធ្វើឱ្យជនរងគ្រោះមិនអាចទទួលបានការព្យាបាលដោយចលនា ឬការថែទាំសុខភាពបន្តបន្ទាប់ឱ្យបានទៀងទាត់ ដែលជាកត្តាចាំបាច់សម្រាប់ទប់ស្កាត់ការវិវត្តទៅជាពិការភាពធ្ងន់ធ្ងរជាងមុន
- កម្ពុជានៅជួបប្រទះកង្វះខាតអ្នកឯកទេសខាងចិត្តវិទ្យាសម្រាប់ព្យាបាលជំងឺបាក់ទឹកចិត្ត និងអ្នកបច្ចេកទេសកម្រិតខ្ពស់ក្នុងការផលិតឧបករណ៍ជំនួយ។ ការផ្តល់សេវាភាគច្រើននៅមានលក្ខណៈ «ប្រមូលផ្តុំនៅថ្នាក់ជាតិ ឬទីរួមខេត្ត» ដែលបង្កើតជាគម្លាតដ៏ធំសម្រាប់ជនរងគ្រោះនៅតំបន់មូលដ្ឋានដាច់ស្រយាល ក្នុងការទទួលបានសេវាប្រកបដោយគុណភាព និងសមធម៌
- ពិការភាព និងភាពក្រីក្រមានទំនាក់ទំនងគ្នាជាលក្ខណៈចក្រពន្ធ។ ពិការភាពនាំឱ្យបាត់បង់ឱកាសរកចំណូល ចំណែកភាពក្រីក្រធ្វើឱ្យជនរងគ្រោះមិនអាចទទួលបានសេវាថែទាំល្អ។ បញ្ហានេះបង្កើតជាវដ្តដ៏គ្រោះថ្នាក់ដែលរុញច្រានក្រុមគ្រួសារជនរងគ្រោះឱ្យធ្លាក់ក្នុងបំណុល និងបង្ខំឱ្យកូនចៅត្រូវបោះបង់ការសិក្សាដើម្បីជួយជីវភាពគ្រួសារ

- ការយល់ដឹងអំពី «គំរូសង្គមនៃពិការភាព» នៅមានកម្រិតនៅឡើយ។ ជនរងគ្រោះខ្លួនឯង និងអាជ្ញាធរមូលដ្ឋានមួយចំនួន នៅតែមានការយល់ច្រឡំថាការជួយជនមានពិការភាពគឺជាអំពើ «សប្បុរសធម៌» ជាជាងការបំពេញកាតព្វកិច្ច «គោរពសិទ្ធិ» និងការផ្តល់សេចក្តីថ្លៃថ្នូរដល់មនុស្សជាតិ។

៧.២. ទិសដៅអនុវត្តសកម្មភាពបន្ត

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាខាងលើ ទិសដៅនាពេលអនាគតត្រូវផ្លាស់ប្តូរពី «ការឆ្លើយតបទៅតាមព្រឹត្តិការណ៍» មកជា «ការកសាងប្រព័ន្ធគាំពារមួយដែលរឹងមាំ និងមានភាពធន់» តាមរយៈយុទ្ធសាស្ត្រគន្លឹះដូចខាងក្រោម៖

➢ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានគ្មានរបាំង

- បង្កើនកិច្ចសហការជិតស្និទ្ធជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីដាក់បញ្ចូលបទដ្ឋានបច្ចេកទេស «រចនាជាសកល» ទៅក្នុងលក្ខខណ្ឌវិនិច្ឆ័យដាច់ខាត និងការចុះអធិការកិច្ចមុននឹងអនុញ្ញាតឱ្យសាងសង់ ឬជួសជុលអគារសាធារណៈ ជាពិសេសសាលារៀន មន្ទីរពេទ្យ និងទីកន្លែងការងារ ដើម្បីធានាថាជនរងគ្រោះអាចចូលប្រើប្រាស់សេវាដោយសមធម៌

- រៀបចំផែនការថវិកាជាតិ និងកៀរគរជំនួយពីដៃគូអភិវឌ្ឍ ដើម្បីកែលម្អជាជំហានៗនូវអគារសាធារណៈអាទិភាព ដោយមានជម្រាលស្តង់ដាសម្រាប់រទេះរុញ បង្គន់អនាម័យជនពិការ ស្លាកសញ្ញា និងផ្លូវដើរសម្រាប់ជនរងគ្រោះដែលមានពិការភាពភ្នែក សំដៅលុបបំបាត់ «ពិការភាពទីពីរ» ដែលបង្កឡើងដោយរបាំងបរិស្ថានជុំវិញ

➢ ការពង្រីកវិសាលភាព និងគុណភាពនៃការផ្គត់ផ្គង់ឧបករណ៍ជំនួយ និងសេវាស្តារលទ្ធភាពពលកម្ម

- ពង្រឹងសមត្ថភាព និងផលិតឧបករណ៍ជំនួយ(រទេះរុញ ឈើច្រត់ អវយវៈសិប្បនិម្មិត និងគ្រឿងរណប) ទាំងបរិមាណ និងគុណភាព ដោយផ្តោតលើការរចនា និងកែច្នៃឱ្យស្របទៅនឹងសណ្ឋានដីតំបន់ជនបទដាច់ស្រយាល និងស្ថានភាពពិការភាពជាក់ស្តែងរបស់ជនរងគ្រោះម្នាក់ៗ

- បង្កើត និងពង្រឹងសមត្ថភាព «មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងផ្តល់សេវាចល័ត» ដើម្បីចុះផ្តល់សេវាជួសជុល ការព្យាបាលដោយចលនា ពិនិត្យសុខភាព និងថែទាំបន្តបន្ទាប់ដល់ផ្ទះជនរងគ្រោះនៅតំបន់ដាច់ស្រយាល សំដៅទប់ស្កាត់ការវិវត្តទៅជាពិការភាពធ្ងន់ធ្ងរជាងមុន

➢ ការបណ្តុះបណ្តាលជំនាញ និងសេវាឯកទេស

- ផ្តល់អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលកម្រិតខ្ពស់ លើជំនាញចិត្តវិទ្យា ដើម្បីព្យាបាលជំងឺបាក់ទឹកចិត្ត និងវិបត្តិផ្លូវចិត្ត របស់ជនរងគ្រោះ ព្រមទាំងបណ្តុះបណ្តាលអ្នកបច្ចេកទេសកម្រិតខ្ពស់ក្នុងការផលិតអវយវៈសិប្បនិម្មិត និងឧបករណ៍ជំនួយ

- បង្កើតប្រព័ន្ធបញ្ជូន និងបង្កើតការផ្តល់សេវាគាំពារផ្លូវចិត្ត និងសេវាបច្ចេកទេសនៅគ្រឹមកម្រិតខេត្ត និងស្រុក(តាមរយៈមន្ទីរពេទ្យបង្អែក ឬមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា) ដើម្បីកាត់

បន្ថយការប្រមូលផ្តុំនៅថ្នាក់ជាតិ ធានាបាននូវភាពងាយស្រួល ថ្លៃចំណាយទាប និងសមធម៌សម្រាប់ជនរងគ្រោះ

➢ **ការបំបែកវដ្តចក្រពន្ធនៃពិការភាព និងភាពក្រីក្រ (ជួយជនមានពិការភាពឱ្យផុតពីភាពក្រីក្រ)**

- រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញសហគ្រិនភាពដែលបត់បែនស្របតាមលទ្ធភាពកាយសម្បទារបស់ជនរងគ្រោះ ព្រមទាំងផ្តល់ទុនចាប់ផ្តើមអាជីវកម្មខ្នាតតូច បង្កើតការងារសហគមន៍ ឬការតភ្ជាប់ទៅកាន់ទីផ្សារការងារ តាមរយៈការតបន្តឹងការអនុវត្តកូតាទទួលជនមានពិការភាពចូលបម្រើការងារក្នុងវិស័យរដ្ឋ និងឯកជន

- ធានាថាគ្រួសារជនរងគ្រោះដែលមានពិការភាពទាំងអស់ ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគាំពារសង្គម(ទទួលបានបណ្ណសមធម៌ ឬកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជាទៀងទាត់) ដើម្បីកាត់បន្ថយបន្ទុកបំណុល និងផ្តល់អាហារូបករណ៍ ឬកញ្ចប់គាំទ្រការសិក្សាដល់កូនចៅរបស់ពួកគេ ដើម្បីបង្ការការបោះបង់ការសិក្សា

➢ **ការផ្លាស់ប្តូរឥរិយាបថសង្គម ផ្តែកលើ «គំរូសង្គមនៃពិការភាព»**

- រៀបចំយុទ្ធនាការអប់រំ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងស៊ីជម្រៅ អំពី «គំរូសង្គមនៃពិការភាព និងសិទ្ធិជនពិការ» តាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិ និងបណ្តាញសង្គម ដើម្បីផ្លាស់ប្តូរការយល់ឃើញរបស់សាធារណជនពីការផ្តល់ «សប្បុរសធម៌ ឬក្តីអាណិតអាសូរ» មកជា «ការបំពេញកាតព្វកិច្ច គោរពសិទ្ធិ និងការផ្តល់សេចក្តីថ្លៃថ្នូរ» ដល់ជនរងគ្រោះ

- រៀបចំវគ្គតម្រង់ទិសដៅ និងបណ្តុះបណ្តាលជាប្រចាំដល់អាជ្ញាធរដែនដី(ភូមិ ឃុំ ស្រុក) ឱ្យយល់ដឹងពីកាតព្វកិច្ចផ្លូវច្បាប់ តួនាទីស្នូលក្នុងការសម្របសម្រួល និងការបង្កើតបរិយាបន្ន ដើម្បីធានាថាជនរងគ្រោះទទួលបានការការពារសិទ្ធិ និងការគាំទ្រពេញលេញនៅក្នុងសហគមន៍របស់ខ្លួន។

៧.៣. អនុសាសន៍

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម និងសម្រេចឱ្យបាននូវទិសដៅសកម្មភាពខាងលើ អនុសាសន៍ជាក់ស្តែងមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

➢ **ការពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងគណនេយ្យភាពអន្តរស្ថាប័ន**

- **អនុសាសន៍** : ត្រូវពង្រឹងយន្តការដឹកនាំ និងសម្របសម្រួលថ្នាក់ជាតិដោយបង្កើត «គណៈកម្មការអន្តរក្រសួង ដើម្បីធ្វើបរិយាបន្នកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ» ដែលមានការចូលរួមពីអាជ្ញាធរមីន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាថាការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិ និងបទដ្ឋាន «រចនាជាសកល» មានសង្គតិភាព និងមិនមានលក្ខណៈដាច់ដោយឡែកពីគ្នា

➢ **ការធានាចីរភាពហិរញ្ញវត្ថុ តាមរយៈគំរូវិនិយោគសាធារណៈ និងវិស័យឯកជន**

- **អនុសាសន៍** : រាជរដ្ឋាភិបាលគួរតែពង្រីកវិសាលភាពនិងកែទម្រង់ «មូលនិធិជាតិសម្រាប់កិច្ចសង្គ្រោះជនរងគ្រោះ» ឱ្យមានចីរភាព តាមរយៈការកៀរគរប្រភពចំណូលចម្រុះ និងការជំរុញការទទួលខុសត្រូវសង្គមរបស់សហគ្រាសឯកជន ដោយមិនពឹងផ្អែកតែលើកញ្ចប់ថវិកាជាតិ ឬជំនួយបរទេសឡើយ

➢ **ការធ្វើទំនើបកម្មប្រព័ន្ធទិន្នន័យជនរងគ្រោះ តាមរយៈបច្ចេកវិទ្យាឌីជីថល**

- **អនុសាសន៍** : ជំរុញការអភិវឌ្ឍ និងដាក់ឱ្យដំណើរការ «ប្រព័ន្ធគ្រប់គ្រងព័ត៌មានជនរងគ្រោះឌីជីថល» ដើម្បីលុបបំបាត់គម្លាតសេវារវាងទីក្រុង និងតំបន់ដាច់ស្រយាល ស្របតាមរបៀបវារៈរដ្ឋាភិបាលឌីជីថល និងផែនការយុទ្ធសាស្ត្រជាតិ

➢ **ការបញ្ចាបសេវាសុខភាពផ្លូវចិត្ត និងស្តារលទ្ធភាពពលកម្មកាយសម្បទាទៅក្នុងប្រព័ន្ធថែទាំសុខភាពបឋម**

- **អនុសាសន៍** : ធ្វើវិមជ្ឈការសេវាឯកទេស ដោយមិនត្រូវទុកឱ្យសេវាព្យាបាលផ្លូវចិត្ត និងសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅប្រមូលផ្តុំតែថ្នាក់ជាតិ ឬទីរួមខេត្តឡើយ។ ក្រសួងសុខាភិបាល និងសង្គមកិច្ចគួរតែបញ្ចូលវគ្គបណ្តុះបណ្តាល «សុខភាពចិត្តវិទ្យាបឋម និងរូបវន្តកិបាលសហគមន៍» ទៅក្នុងកម្មវិធីសិក្សាសម្រាប់និស្សិតពេទ្យ គិលានុបដ្ឋាក និងឆ្មប ក៏ដូចជាពង្រីកសេវាស្តារឱ្យដល់មូលដ្ឋាន

➢ **ការផ្លាស់ប្តូរទម្រង់យុទ្ធនាការពី «ការផ្សព្វផ្សាយបែបប្រពៃណី» ទៅជា «ការអនុវត្តច្បាប់តឹងរឹង»**

- **អនុសាសន៍** : ស្របពេលដែលការអប់រំអំពី «គំរូសង្គមនៃពិការភាព» ត្រូវធ្វើជាបន្តបន្ទាប់ ស្ថាប័នមានសមត្ថកិច្ចត្រូវផ្លាស់ប្តូរឥរិយាបថ និងយុទ្ធសាស្ត្រគាំទ្រ ពីការអង្វរករសុំសប្បុរសធម៌ ឬក្តីអាណិតអាសូរមកជា «ការដោះស្រាយតាមផ្លូវច្បាប់ និងការការពារសិទ្ធិជាមូលដ្ឋាន» វិញក្នុងនាមជាអ្នកអនុវត្តច្បាប់ និងអនុសញ្ញាសិទ្ធិជនពិការអន្តរជាតិ។

ជំពូកទី៨៖ ការត្រួតពិនិត្យ និងវាយតម្លៃ

ការត្រួតពិនិត្យ និងតាមដានវាយតម្លៃ គឺជាឧបករណ៍យុទ្ធសាស្ត្រដ៏មានសារៈសំខាន់សម្រាប់វាស់វែងវឌ្ឍនភាព ធានាគុណភាពសេវា និងកែលម្អប្រសិទ្ធភាពនៃកិច្ចអន្តរាគមន៍ចំពោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ជំពូកនេះកំណត់នូវក្របខ័ណ្ឌការងាររួម ដើម្បីធានាឱ្យបាននូវតម្លាភាព គណនេយ្យភាព និងការសម្រេចឱ្យបាននូវចក្ខុវិស័យ «មិនបោះបង់ជនរងគ្រោះណាម្នាក់ចោល» ។

៨.១. គោលការណ៍គ្រឹះនៃប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីធានាបាននូវគុណភាព ប្រព័ន្ធតាមដានត្រូវអនុវត្តតាមគោលការណ៍អាទិភាពចំនួន៤៖

- ធានាថាគ្រប់សកម្មភាពឆ្លើយតបចំតម្រូវការជាក់ស្តែងរបស់ជនរងគ្រោះ និងស្របតាមគោលនយោបាយផែនការយុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តជាតិ។ ទិន្នន័យត្រូវវិភាគដោយបែងចែកតាម ភេទ អាយុ និងប្រភេទពិការភាព ដើម្បីកំណត់មុខសញ្ញាងាយរងគ្រោះបំផុត
- ផ្តោតលើការប្រើប្រាស់ធនធាន និងពេលវេលាឱ្យមានផលចំណេញខ្ពស់បំផុតដោយកាត់បន្ថយការងារត្រួតស៊ីគ្នារវាងស្ថាប័នរដ្ឋ និងអង្គការដៃគូ តាមរយៈការធ្វើបរិយាបន្នទិន្នន័យ

- ធ្វើការវាស់វែងលទ្ធផលផ្តែកលើកស្តុតាង តាមរយៈការស្វង់មតិ និងការសម្ភាសន៍ផ្ទាល់ជាមួយជនរងគ្រោះ ដើម្បីវាយតម្លៃកម្រិតនៃការពេញចិត្ត និងគុណភាពសេវាកម្ម
- កសាងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃឱ្យទៅជាយន្តការជាតិយូរអង្វែង និងពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ជាតិនិងក្រោមជាតិ ដើម្បីជានាការបន្តគាំទ្រដល់ជនរងគ្រោះ។

៨.២. ទំនួលខុសត្រូវរបស់អាជ្ញាធរមីន

ក្នុងនាមជាស្ថាប័នសម្របសម្រួលថ្នាក់ជាតិ អាជ្ញាធរមីនមានការកិច្ច៖

- បង្កើតក្រុមការងារបច្ចេកទេសចម្រុះដើម្បីតាមដានការអនុវត្តការងារស្របតាមគោលការណ៍ណែនាំ
- រៀបចំកិច្ចប្រជុំគណៈកម្មការបច្ចេកទេសចម្រុះ (ប្រចាំត្រីមាស ឬឆមាស) រវាងក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាល ក្រសួងការងារ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យវឌ្ឍនភាព និងដោះស្រាយភាពមិនស៊ីសង្វាក់គ្នានៃការផ្តល់សេវា
- ដឹកនាំការរៀបចំសេចក្តីណែនាំស្តីពីការបញ្ជូនជនរងគ្រោះពីតំបន់រងគ្រោះថ្នាក់ដោយធានាការតភ្ជាប់រវាងការសង្គ្រោះបន្ទាន់ ការព្យាបាល ការស្តារលទ្ធភាពពលកម្មកាយសម្បទា និងការធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម
- ជំរុញ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងអង្គការជាតិ អន្តរជាតិ ដើម្បីបែងចែកតំបន់ប្រតិបត្តិការ ជៀសវាងការជាន់គ្នានៃការផ្តល់ជំនួយ
- ប្រមូល ផ្ទៀងផ្ទាត់ និងបញ្ចូលទិន្នន័យជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យឱ្យបានទៀងទាត់ និងត្រឹមត្រូវ
- ដឹកនាំការតភ្ជាប់ប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរមីន ជាមួយប្រព័ន្ធអត្តសញ្ញាណកម្មពិការភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបណ្តាសមជម៌ ដើម្បីធានាថាជនរងគ្រោះទទួលបានបណ្តាគាំពារសង្គម
- ចែករំលែកទិន្នន័យជនរងគ្រោះដែលបានវិភាគរួច (តាមខេត្ត ស្រុក ភេទ និងប្រភេទពិការភាព) ទៅកាន់ក្រសួងសាមី ដើម្បីឱ្យពួកគេអាចរៀបចំកញ្ចប់ថវិកា និងសេវាឆ្លើយតបចំគោលដៅ
- ចូលរួមប្រជុំ និងការពារថវិកាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដើម្បីធានាថាកិច្ចសង្គ្រោះជនរងគ្រោះត្រូវបានដាក់បញ្ចូលជាអាទិភាពជាតិ
- ផ្តល់យោបល់បច្ចេកទេស និងតស៊ូមតិជាមួយក្រសួងពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តកូតាការងារ (២% សម្រាប់រដ្ឋ និង១% សម្រាប់ឯកជន) និងស្តង់ដាសំណង់អគារគ្មានរបាំង
- ចុះសិក្សា និងវាយតម្លៃលើការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិនៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា មន្ទីរពេទ្យ មណ្ឌលសុខភាព និងសហគមន៍ជនរងគ្រោះ ដើម្បីវាយតម្លៃគុណភាពសេវា និងឧបករណ៍ជំនួយ
- ចុះប្រមូលព័ត៌មានលម្អិតភ្លាមៗបន្ទាប់ពីមានករណីផ្ទុះគ្រាប់មីន ឬយុទ្ធភណ្ឌគ្រឿងផ្ទុះ (រួមមានអត្តសញ្ញាណជនរងគ្រោះ ប្រភេទរបួស ទីតាំង និងស្ថានភាពគ្រួសារ)

- រៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់ប្រចាំឆ្នាំ ជាក់ជូនប្រមុខរាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ស្របតាមកាតព្វកិច្ចនៃអនុសញ្ញាអូតាវ៉ា។

៨.៣. ចំណុលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាល

- ទទួលខុសត្រូវលើការដឹកនាំ និងសម្របសម្រួលការផ្តល់សេវាគាំពារសង្គម របបសន្តិសុខសង្គម និងការបង្កើតកម្មវិធីជំនួយសង្គមសម្រាប់ជនរងគ្រោះ និងគ្រួសារ
- គ្រប់គ្រង ធ្វើទំនើបកម្ម និងពង្រីកវិសាលភាពមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាឱ្យនៅជិតសហគមន៍ ព្រមទាំងជានាការផ្គត់ផ្គង់ឧបករណ៍ជំនួយ(រទេះរុញ ឈើច្រត់ អវយវៈសិប្បនិម្មិត) ដោយឥតគិតថ្លៃ និងមានគុណភាព
- ដឹកនាំការចុះបញ្ជី និងកំណត់កម្រិតពិការភាពតាមប្រព័ន្ធឌីជីថល ដើម្បីជានាថាជនរងគ្រោះទទួលបានបណ្ណពិការភាព និងកញ្ចប់ឧបត្ថម្ភសង្គមបានទាន់ពេលវេលា
- ជានាថាជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់ ការវះកាត់ និងការព្យាបាលមុខរបួសដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋ តាមរយៈយន្តការ «បណ្ណសមធម៌» ឬ «មូលនិធិសមធម៌សុខាភិបាល»
- បញ្ចូលការបណ្តុះបណ្តាល «សុខភាពចិត្តវិទ្យាបឋម និងរូបវន្តភិបាល» ទៅក្នុងមណ្ឌលសុខភាពឃុំសង្កាត់ និងមន្ទីរពេទ្យបង្អែកស្រុក ដើម្បីផ្តល់ការព្យាបាលផ្លូវចិត្ត និងការស្តារកាយសម្បទាបឋមនៅមូលដ្ឋាន
- ជានាថាជនរងគ្រោះ និងកូនចៅរបស់ជនរងគ្រោះទទួលបានអាហារូបករណ៍ ឬការលើកលែងថ្លៃសិក្សា ព្រមទាំងការគាំទ្រសម្ភារសិក្សា ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា
- រៀបចំកម្មវិធីសិក្សា បច្ចេកទេសបង្រៀន និងឧបករណ៍ជំនួយសិក្សា(ដូចជា អក្សរស្នាប ភាសាកាយវិការ) ដើម្បីសម្រួលដល់ការរៀនសូត្ររបស់សិស្ស-និស្សិតដែលមានពិការភាព ឬជាជនរងគ្រោះ
- កែលម្អ និងសាងសង់អគារសិក្សា ផ្លូវដែជម្រាល និងបន្ទប់ទឹកនៅតាមគ្រឹះស្ថានសិក្សាសាធារណៈឱ្យស្របតាមស្តង់ដា "រចនាជាសកល" ដើម្បីឱ្យសិស្សពិការធ្វើដំណើរដោយស្វ័យប្រវត្តិ
- បញ្ឈប់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងផ្ទុះ និងការលុបបំបាត់ការរើសអើង ការបណ្តេញសិស្សពិការទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន ជាពិសេសនៅតំបន់ប្រឈមហានិភ័យខ្ពស់
- បណ្តុះបណ្តាលលោកគ្រូ អ្នកគ្រូឱ្យយល់ដឹងពីការគាំទ្រផ្លូវចិត្តបឋម ដើម្បីជួយសម្រួលដល់សិស្សរងគ្រោះឱ្យមានទំនុកចិត្ត និងចូលរួមសកម្មភាពសាលាបានពេញលេញ
- រៀបចំ និងត្រួតពិនិត្យបទដ្ឋានបច្ចេកទេសសំណង់ ដើម្បីជានាថារាល់អគារសាធារណៈ(សាលារៀន មន្ទីរពេទ្យ ស្ថាប័នរដ្ឋ) និងហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសាធារណជន ត្រូវតែមានផ្លូវដែជម្រាល បន្ទប់ទឹក និងមធ្យោបាយសម្រួលដល់ជនមានពិការភាព
- បដិសេធមិនអនុម័តប្លង់ ឬមិនផ្តល់លិខិតអនុញ្ញាតឱ្យបើកប្រកបអាជីវកម្ម ប្រើប្រាស់អគារសាធារណៈណាដែលមិនបានរៀបចំជម្រាល ឬមធ្យោបាយងាយស្រួលសម្រាប់ជនពិការ
- ជំរុញ និងតាមដានការអនុវត្តច្បាប់ស្តីពីកូតាការងារជនពិការ (២% សម្រាប់ស្ថាប័នរដ្ឋ និង ១% សម្រាប់សហគ្រាសឯកជន) និងផាកពិន័យក្រុមហ៊ុន ស្ថាប័នដែលមិនអនុវត្តតាមច្បាប់

- រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញរៀនជីវៈដែលឆ្លើយតបនឹងទីផ្សារការងារ និងសម្របតាមកាយសម្បទារបស់ជនរងគ្រោះ ព្រមទាំងសម្របសម្រួលការទទួលបានការងារធ្វើ ឬទុនបង្វិលបង្កើតមុខរបរ
- គ្រោង និងបែងចែកកញ្ចប់ថវិកាជាតិឱ្យបានសមស្រប និងប្រកបដោយចីរភាព សម្រាប់គាំទ្រដល់ «មូលនិធិជាតិសម្រាប់កិច្ចសង្គ្រោះជនរងគ្រោះ» និងកម្មវិធីគាំពារសង្គមនានា
- រៀបចំគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធ ឬការលើកលែងពន្ធនាំចូល ដល់សហគ្រាសដែលផលិតឧបករណ៍ជំនួយបច្ចេកទេស ឬក្រុមហ៊ុនដែលទទួលជនរងគ្រោះចូលបម្រើការងារលើសកូតាកំណត់
- ស្រង់ទិន្នន័យ សម្របសម្រួល និងឆ្លើយតបភ្លាមៗនៅពេលមានគ្រោះថ្នាក់កើតឡើង ព្រមទាំងជួយសម្របសម្រួលឱ្យជនរងគ្រោះទទួលបានសេវាសង្គមកិច្ច សុខាភិបាល និងបណ្ណាក្រីក្រ បណ្ណពិការភាព
- បញ្ចូលតម្រូវការរបស់ជនរងគ្រោះនិងជនមានពិការភាពទៅក្នុង «ផែនការវិនិយោគឃុំ សង្កាត់» និង «ផែនការអភិវឌ្ឍស្រុក ខណ្ឌ» (ដូចជា ការកសាងផ្លូវដែម្រាលនៅសាលាឃុំ ការផ្តល់អាហារូបករណ៍ដល់កូនចៅជនរងគ្រោះ)។

៨.៤. ចំនួលខុសត្រូវរបស់ប្រតិបត្តិការសកម្មភាពមីន

ប្រតិបត្តិការសកម្មភាពមីនដែលអនុវត្តការងារផ្ទាល់មានការកិច្ច៖

- ផ្តល់ការសង្គ្រោះបឋមនៅកន្លែងកើតហេតុដោយធានាថាគ្រប់ក្រុមកងរបោសសម្អាតមីន និងយុទ្ធកណ្ឌមិនទាន់ផ្ទុះទាំងអស់សុទ្ធតែមានសម្ភារបរិក្ខារពេទ្យ និងបុគ្គលិកបានបណ្តុះបណ្តាលជំនាញសង្គ្រោះបឋម ដើម្បីអន្តរាគមន៍ភ្លាមៗដល់ប្រជាពលរដ្ឋ ឬកងកម្លាំងដែលរងគ្រោះថ្នាក់ក្នុង ឬក្បែរតំបន់ប្រតិបត្តិការ
- រៀបចំ និងសហការជាមួយមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាពដែលនៅជិតបំផុត ដើម្បីបញ្ជូនជនរងគ្រោះទៅសង្គ្រោះបន្ទាន់ឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយអត្រាមរណភាព និងទប់ស្កាត់ការវិវត្តទៅជា ពិការភាពធ្ងន់ធ្ងរ
- បណ្តុះបណ្តាលក្រុមការងារចុះទីវាលផ្ទាល់ឱ្យចេះបច្ចេកទេសសម្រាលទុក្ខ និងផ្តល់ការលើកទឹកចិត្តបឋមដល់ជនរងគ្រោះ និងក្រុមគ្រួសារភ្លាមៗក្រោយពេលជួបឧបទ្ទវហេតុដោយសារយុទ្ធកណ្ឌគ្រឿងផ្ទុះ
- បញ្ជ្រាបការអប់រំអំពីគ្រោះថ្នាក់នៃយុទ្ធកណ្ឌគ្រឿងផ្ទុះដល់សហគមន៍ងាយរងគ្រោះ និងការណែនាំជនរងគ្រោះឱ្យយល់ដឹងអំពីសិទ្ធិរបស់ខ្លួន និងបណ្តាញស្វែងរកជំនួយ(ដូចជា សេវាឧបករណ៍ជំនួយ សេវាប័ណ្ណសមធម៌) ស្របតាមគោលការណ៍ណែនាំថ្នាក់ជាតិ
- ផ្តល់អាទិភាពដល់ជនរងគ្រោះដោយសារមីន ឬយុទ្ធកណ្ឌគ្រឿងផ្ទុះដែលមានកាយសម្បទាអាចធ្វើការបាន ឱ្យចូលបម្រើការងារនៅក្នុងស្ថាប័នប្រតិបត្តិការផ្ទាល់(ដូចជាធ្វើជាភ្នាក់ងារអប់រំកាត់បន្ថយហានិភ័យមន្ត្រីរដ្ឋបាល ឬអ្នកបច្ចេកទេសស្រាលៗ)
- ធានាថាដីដែលបោសសម្អាតរួច ត្រូវបានប្រគល់ជូនចំគ្រួសារជនរងគ្រោះ និងប្រជាពលរដ្ឋក្រីក្រ ដើម្បីឱ្យពួកគេបានដីមានសុវត្ថិភាពសម្រាប់ធ្វើកសិកម្ម សាងសង់លំនៅឋាន ឬហេដ្ឋារចនាសម្ព័ន្ធសហគមន៍ សំដៅជួយជនមានពិការភាពឱ្យផុតពីភាពក្រីក្រ

- ធ្វើការជិតស្និទ្ធជាមួយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមខេត្ត ដើម្បីជួយសម្របសម្រួល និងណែនាំជនរងគ្រោះថ្មីៗឱ្យទទួលបានអវយវៈសិប្បនិម្មិត ឬរទេះរុញបានលឿន និងស្របតាមស្ថានភាពដីដែលពួកគេរស់នៅ
- ចូលរួមលើកកម្ពស់ «គំរូសង្គមនៃពិការភាព» នៅក្នុងគ្រប់សកម្មភាពចុះជួបប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដោយផ្លាស់ប្តូរការយល់ឃើញពីការផ្តល់ជំនួយបែបអាណិតអាសូរមកជាការបំពេញកាតព្វកិច្ច និងការផ្តល់សេចក្តីថ្លៃថ្នូរដល់ជនរងគ្រោះ។

៨.៥. ចំនួលខុសត្រូវរបស់អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ

អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះមានការកិច្ច៖

- ការផ្តល់សេវាគាំពារផ្លូវចិត្ត និងចិត្តសង្គម
  - អ្នកផ្តល់សេវាត្រូវរៀបចំកម្មវិធីប្រឹក្សា និងព្យាបាលជំងឺបាក់ទឹកចិត្ត ឬវិបត្តិផ្លូវចិត្តក្រោយរងគ្រោះថ្នាក់ដល់ជនរងគ្រោះ និងក្រុមគ្រួសារជាប្រព័ន្ធ មិនមែនធ្វើឡើងតែមួយដងនោះឡើយ
  - សម្របសម្រួលបង្កើតបណ្តាញជនរងគ្រោះជួយជនរងគ្រោះ(មិត្តអប់រំមិត្ត) ដើម្បីចែករំលែកបទពិសោធន៍ ការលើកទឹកចិត្ត និងការកសាងភាពធន់ក្នុងចិត្តឡើងវិញ
- ការសម្របសម្រួលកញ្ចប់ជំនួយសេដ្ឋកិច្ច និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
  - អ្នកផ្តល់សេវាផ្នែកអភិវឌ្ឍន៍ សិប្បកម្ម ត្រូវរៀបចំវគ្គបណ្តុះបណ្តាលលើជំនាញវិជ្ជាជីវៈ ឬសហគ្រិនភាពដែលបត់បែន ស្របតាមកាយសម្បទាជាក់ស្តែងរបស់ជនរងគ្រោះ និងតម្រូវការទីផ្សារការងារជាក់ស្តែង
  - ជួយសម្របសម្រួល និងណែនាំជនរងគ្រោះឱ្យទទួលបានបណ្ណសមធម៌ ការចុះឈ្មោះតាមប្រព័ន្ធអត្តសញ្ញាណកម្មពិការភាព និងការទទួលបានកម្ចីខ្នាតតូចគ្មានការប្រាក់ដើម្បីបង្កើតមុខរបរ
- គណនេយ្យភាពទិន្នន័យ និងការការពារសិទ្ធិជនរងគ្រោះ
  - កត់ត្រា និងធ្វើបច្ចុប្បន្នភាពទិន្នន័យជនរងគ្រោះដែលមកទទួលសេវារួចបញ្ជូនទៅកាន់ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់រដ្ឋ ដោយធានាបាននូវការរក្សាការសម្ងាត់ និងឯកជនភាពរបស់ជនរងគ្រោះ
  - អនុវត្តការផ្តល់សេវាដោយឈរលើ «គំរូសង្គមនៃពិការភាព» ចាត់ទុកជនរងគ្រោះជាម្ចាស់សិទ្ធិ មិនមែនជាកម្មវត្ថុនៃក្តីអាណិតអាសូរឡើយ ព្រមទាំងចូលរួមផ្សព្វផ្សាយ និងតស៊ូមតិប្រឆាំងនឹងការរើសអើងគ្រប់ទម្រង់នៅក្នុងស្ថាប័ន និងសហគមន៍។

ជំពូកទី៩៖ សេចក្តីសន្និដ្ឋាន និងការអំពាវនាវ

កិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធកណ្តាប្រឹងផ្ទុះនៅកម្ពុជា មិនត្រឹមតែជាកាតព្វកិច្ចមនុស្សធម៌ដ៏ចម្បងដែលមិនអាចខ្វះបានប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការវិនិយោគយុទ្ធសាស្ត្រលើវិស័យសិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន ដើម្បីធានាថា «គ្មាននរណាម្នាក់ត្រូវបានបោះបង់ចោល» ពីផលប្រយោជន៍នៃកំណើនសេដ្ឋកិច្ច និងការរីកចម្រើនរបស់សង្គមជាតិនោះឡើយ។ ផ្អែកលើការវិភាគលើវឌ្ឍនភាពកន្លងមក ទោះបីជាកម្ពុជា សម្រេចបាននូវលទ្ធផលគួរឱ្យមោទនៈក្នុងកិច្ចគាំពារជនមានពិការភាពក៏ដោយ ជនរងគ្រោះនៅតែបន្តប្រឈមមុខនឹងរបាំងពហុវិស័យដ៏ស្មុគស្មាញ

ជាពិសេសគឺគម្លាតនៃលទ្ធភាពទទួលបានសេវាគាំទ្រនៅតាមតំបន់ដាច់ស្រយាល កម្រិតនៃទិន្នន័យជាក់លាក់សម្រាប់រៀបចំផែនការ និងបញ្ហានិរន្តរភាពនៃហិរញ្ញវត្ថុដែលនៅមានការពឹងផ្អែកខ្លាំងលើជំនួយពីខាងក្រៅ។ ទោះជាយ៉ាងនេះក្តី កម្ពុជានៅតែមានឱកាសក្នុងការបំបែករបាំងទាំងនេះ តាមរយៈការធ្វើទំនើបកម្មបច្ចេកវិទ្យាជំនួយ ការពង្រឹងប្រព័ន្ធថែទាំសុខភាពផ្លូវចិត្តដល់កម្រិតសហគមន៍ និងការជំរុញធ្វើបរិយាបន្នសេដ្ឋកិច្ច ដែលជាសសរស្តម្ភដ៏រឹងមាំក្នុងការលើកកម្ពស់គុណភាពជីវិត និងការស្តារនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ក្នុងស្មារតីឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យ «កម្ពុជាគ្មានមីន និងបរិយាបន្នសម្រាប់គ្រប់រូប» យើងសូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ ម្ចាស់ជំនួយ វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់ឱ្យបន្តបង្កើនការប្តេជ្ញាចិត្តតាមរយៈការវិនិយោគកាន់តែខ្លាំងលើកម្មវិធីបណ្តុះបណ្តាលផ្ទៃដីវិៈ ការស្តារលទ្ធភាពពលកម្មកាយសម្បទា ការធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម ផ្តល់ការងារ សុខាភិបាល និងសេវាសុខភាពផ្លូវចិត្តឯកទេសនៅកម្រិតមូលដ្ឋានឱ្យកាន់តែទូលំទូលាយ។ ទន្ទឹមនឹងនេះ ការផ្តល់សិទ្ធិអំណាច និងការជំរុញការចូលរួមដឹកនាំប្រកបដោយអត្ថន័យពីសំណាក់ជនរងគ្រោះផ្ទាល់ និងសមាគមជនមានពិការភាព នៅក្នុងដំណើរការតាក់តែងគោលនយោបាយ និងការសម្រេចចិត្ត គឺជារឿងចាំបាច់បំផុតដើម្បីធានាបាននូវគុណភាព ការឆ្លើយតប និងសង្គតិភាពនៃសេវាកម្ម។ លើសពីនេះ កិច្ចខិតខំប្រឹងប្រែងរួមត្រូវតែបន្តផ្តោតលើការធ្វើបរិយាបន្នលើផ្នែកកិច្ចសង្គ្រោះជនរងគ្រោះទៅក្នុងប្រព័ន្ធគាំពារសង្គមជាតិ ជារួម ដើម្បីធានានូវការគាំទ្រយូរអង្វែង និងភាពម្ចាស់ការប្រកបដោយនិរន្តរភាពដែលកើតចេញពីធនធានផ្ទាល់របស់ជាតិ។

ជាទីបញ្ចប់ យើងសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុតចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមជាកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី និងធនធានក្នុងកិច្ចការដ៏ឧត្តុង្គឧត្តមដើម្បីមនុស្សជាតិមួយនេះ។ ភាពជាដៃគូដ៏រឹងមាំដែលយើងបានកសាងឡើង មិនត្រឹមតែជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធគាំទ្រដ៏មានសមធម៌ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការផ្តល់នូវពន្លឺនៃក្តីសង្ឃឹម សុវត្ថិភាព និងការផ្លាស់ប្តូរជីវិតរបស់ជនរងគ្រោះឱ្យមានភាពរស់រវើកឡើងវិញ ដើម្បីឱ្យពួកគាត់អាចរស់នៅដោយមានមោទនភាព មានភាពម្ចាស់ការលើវាសនាខ្លួនឯង និងមានសេចក្តីថ្លៃថ្នូរពេញលេញនៅក្នុងសហគមន៍ ក៏ដូចជាក្នុងសង្គមជាតិទាំងមូលជានិរន្តរ៍។

ឧបសម្ព័ន្ធ "ក"

តារាងត្រួតពិនិត្យការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ជំពូក	ផ្នែក	មាតិកាបញ្ជីត្រួតពិនិត្យ	អ្នកឧបត្ថម្ភសម្ភារៈ	ស្ថានភាពអនុវត្ត
ជំពូកទី១៖ សេចក្តីផ្តើម	▪ **បញ្ជីត្រួតពិនិត្យទូទៅ**	▪ គ្រប់ផ្នែក និងវិស័យពាក់ព័ន្ធមាន និងបានប្រើប្រាស់បញ្ជីត្រួតពិនិត្យនេះ ដើម្បីវាយតម្លៃការអនុលោមតាមគោលការណ៍ណែនាំថ្នាក់ជាតិ	គ្រប់ភាគីពាក់ព័ន្ធ(អាជ្ញាធរមីន ប្រតិបត្តិករ ក្រសួង ស្ថាប័ន អង្គការអ្នកផ្តល់សេវា)	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ប្រើប្រាស់បញ្ជីត្រួតពិនិត្យនេះសម្រាប់ការធ្វើតាមដានការងារផ្ទៃក្នុង និងខាងក្រៅជាប្រចាំ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ប្រើប្រាស់បញ្ជីនេះដើម្បីបង្កើតស្តង់ដាប្រតិបត្តិការ (SOP) ថ្មី និងពិនិត្យឡើងវិញនូវស្តង់ដាបច្ចុប្បន្ន	អាជ្ញាធរមីន ប្រតិបត្តិករ អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ចាត់វិធានការជាក់ស្តែងដើម្បីស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសអាជ្ញាធរមីន	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី២៖ គោលការណ៍នៃកិច្ចសង្គ្រោះជនរងគ្រោះ	▪ **ការអនុលោមភាពទូទៅ**	▪ ធ្វើការអាន និងស្វែងយល់អំពីស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ជំពូកទី២៣	គ្រប់ភាគីពាក់ព័ន្ធ(អាជ្ញាធរមីន ប្រតិបត្តិករ ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា)	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ចុះឈ្មោះជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងជូនដំណឹងមកអាជ្ញាធរមីនអំពីសកម្មភាពនៃកិច្ចសង្គ្រោះជនរងគ្រោះ	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ទទួលបានសេចក្តីសង្ខេបពីអាជ្ញាធរមីនស្តីពីសកម្មភាពនៃកិច្ចសង្គ្រោះជនរងគ្រោះ និងគោលនយោបាយបច្ចុប្បន្ន	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតនីតិវិធីផ្ទៃក្នុងឱ្យស្របតាមស្តង់ដាជំពូកទី២៣ និងគោលការណ៍ណែនាំ	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

	▪ **ការមិនរើសអើង**	▪ មាននីតិវិធីហាមឃាត់ការរើសអើងដោយផ្អែកលើពិការភាព ភេទ អាយុ ជាតិសាសន៍។ល។	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បណ្តុះបណ្តាលបុគ្គលិក ១០០% លើការអនុវត្តរួម ដោយមិនមានការរើសអើង	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ មានដំណើរការ (នីតិវិធី) ដើម្បីត្រួតពិនិត្យការផ្តល់សេវា ដោយធានាឱ្យមានការព្យាបាលប្រកបដោយសមធម៌ចំពោះជនរងគ្រោះ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ការចូលរួម និងការធ្វើបរិយាបន្ន**	▪ បង្កើតឱ្យមានដំណើរការផ្លូវការសម្រាប់ធ្វើការប្រឹក្សាដល់ជនរងគ្រោះ និងអង្គការជនមានពិការភាព	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រួមបញ្ចូលជនរងគ្រោះធ្វើការយ៉ាងសកម្មក្នុងការរៀបចំផែនការសេវាកម្ម និងការសម្រេចចិត្ត	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ប្រមូល និងបញ្ចូលមតិកែលម្អពីជនរងគ្រោះជាទៀងទាត់ទៅក្នុងកម្មវិធីឱ្យកាន់តែប្រសើរឡើង	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **តារាងយុទ្ធសូល**	▪ មានដំណើរការ និងនីតិវិធីដើម្បីវាយតម្លៃ និងដកចេញនូវឧបសគ្គខាងផ្នែករាងកាយ ហិរញ្ញវត្ថុ និងវប្បធម៌ចំពោះការទទួលបានសេវាកម្ម	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ អនុលោមតាមច្បាប់ និងការធ្វើបរិយាបន្នពិការភាព ដើម្បីផ្តល់កន្លែងស្នាក់នៅឱ្យសមរម្យសម្រាប់អ្នកដែលមានពិការភាពជាក់លាក់ ដែលមានតម្រូវការផ្នែកអប់រំ និងវប្បធម៌	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធានាថាទម្រង់នៃការទាក់ទង និងភាសាដែលអាចប្រើប្រាស់បាន	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

	▪ **ដោះស្រាយតាមចាយរងគ្រោះ**	▪ កំណត់ក្រុមដែលងាយរងគ្រោះ និងសេវាកម្ម ដើម្បីបំពេញតម្រូវការជាក់លាក់របស់ពួកគេ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បណ្តុះបណ្តាលបុគ្គលិកឱ្យទទួលស្គាល់ និងឆ្លើយតបទៅនឹងកត្តាដែលបង្កើនភាពងាយរងគ្រោះ	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **អាយុ យេនឌ័រ ពិការភាព និងភាពចម្រុះ**	▪ បែងចែកទិន្នន័យតាមអាយុ ភេទ និងប្រភេទពិការភាព សម្រាប់ការរៀបចំផែនការ និងការត្រួតពិនិត្យ	អាជ្ញាធរមីន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ កែសម្រួលសេវាកម្មសម្រាប់តម្រូវការនៃក្រុមមនុស្សផ្សេងៗគ្នា	អ្នកផ្តល់សេវា/អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **និរន្តរភាព និងការទទួលខុសត្រូវថ្នាក់ជាតិ**	▪ រៀបចំសេវាកម្មឱ្យស្របនឹងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ និងការចាត់អាទិភាព	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតផែនការចរិការយៈពេលវែងជាមួយនឹងការរួមចំណែកពីក្នុងស្រុក	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ទិដ្ឋភាពស្តង់ដែកលើសិទ្ធិ**	▪ ផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីសិទ្ធិ និងកិច្ចការពារផ្លូវច្បាប់	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតប្រព័ន្ធដើម្បីរក្សាបុគ្គលិក និងដៃគូទទួលខុសត្រូវក្នុងការគោរពសិទ្ធិជនរងគ្រោះ	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ការអនុវត្តផ្អែកលើភស្តុតាង**	▪ ប្រើប្រាស់ទិន្នន័យ និងការស្រាវជ្រាវដែលអាចទុកចិត្តបាន ដើម្បីធ្វើការណែនាំក្នុងការផ្តល់សេវាកម្ម	អាជ្ញាធរមីន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ ពិនិត្យ និងធ្វើបច្ចុប្បន្នភាពកម្មវិធីជាប្រចាំដោយផ្អែកលើកស្តុតាង និងការបញ្ចូលជនរងគ្រោះ	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ការសម្របសម្រួល**	▪ ចែករំលែករបាយការណ៍ និងទិន្នន័យប្រចាំត្រីមាសជាមួយអាជ្ញាធរមីន និងក្រសួង ស្ថាប័នពាក់ព័ន្ធ	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ចូលរួមក្នុងកិច្ចប្រជុំសម្របសម្រួលផ្នែកកិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ជាតិ និងផ្តល់កិច្ចសហការ	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី៣៖ សមាសភាពនៃកិច្ចសង្គ្រោះជនរងគ្រោះ	▪ **ការប្រមូលទិន្នន័យ**	▪ បណ្តុះបណ្តាលបុគ្គលិកលើការប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យ និងគោរពច្បាប់ឯកជនភាព	អាជ្ញាធរមីន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សម្របសម្រួលជាមួយអាជ្ញាធរមីន និងដៃគូផ្សេងទៀត ដើម្បីជៀសវាងការជាន់ទិន្នន័យគ្នា	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ប្រមូល និងធ្វើបច្ចុប្បន្នភាពលើការញែកទិន្នន័យតាម ភេទ អាយុ និងពិការភាព ជាប្រចាំសម្រាប់ជនរងគ្រោះ	អាជ្ញាធរមីន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ប្រើប្រាស់ទម្រង់ស្តង់ដាសម្រាប់ការរាយការណ៍ និង ការបញ្ជូនទិន្នន័យ	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រក្សាទុក និងបម្រុងទុកទិន្នន័យប្រកបដោយសុវត្ថិភាពជាមួយនឹងការចូលប្រើប្រាស់មានដែនកំណត់	អាជ្ញាធរមីន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ចែករំលែកការរកឃើញសំខាន់ៗ និងរក្សាបញ្ជីសេវាកម្មដែលមានស្រាប់	អាជ្ញាធរមីន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

	▪ **ការសង្គ្រោះបន្ទាន់ និងការថែទាំវេជ្ជសាស្ត្រ**	▪ បណ្តុះបណ្តាលបុគ្គលិកយ៉ាងតិច ៧៥% ពីការសង្គ្រោះបឋម និងការសង្គ្រោះចលនាបេះដូង	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បំពាក់គ្រប់យានជំនិះជាមួយនឹងឧបករណ៍សង្គ្រោះបឋមឱ្យបានពេញលេញ	ប្រតិបត្តិករ អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតផែនការជម្លៀសជនរងគ្រោះឱ្យបានច្បាស់លាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីទំនាក់ទំនងជាមួយមន្ទីរពេទ្យ	ប្រតិបត្តិករ អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សហការជាមួយមន្ទីរពេទ្យដើម្បីធានាការប៉ះទង្គិច និងការគ្រប់គ្រងការឆ្លងមេរោគ	ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ផ្តល់ជំនួយជាហិរញ្ញវត្ថុសម្រាប់ការថែទាំសុខភាព និងការដឹកជញ្ជូន	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតយន្តការបញ្ជូនទៅកាន់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ការស្តារលទ្ធភាពពលកម្មកាយសម្បទា**	▪ ធានាថាមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាបានបណ្តុះបណ្តាលបុគ្គលិក (អ្នកជំនាញផលិតអវៈយវៈសិប្បនិម្មិត ព្យាបាលដោយចលនា និងអ្នកធ្វើការផ្នែកសង្គម) តាមចំនួនដែលបានកំណត់ចំពោះសមាមាត្រនៃអ្នកជំងឺ	ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ផ្តល់ជូនគ្រឿងឧបករណ៍ជំនួយដោយឥតគិតថ្លៃ ឬតម្លៃទាប	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ផ្តល់សេវាកម្មឱ្យស្របទៅតាម ភេទ អាយុ និងពិការភាព	អ្នកផ្តល់សេវា អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ រៀបចំថវិកាសម្រាប់ថ្លៃធ្វើដំណើរ និងដឹកជញ្ជូន ដើម្បីផ្តល់ជូនដល់ជនរងគ្រោះទៅទទួលសេវាកម្ម	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ គាំទ្រក្រុមការងារផ្សព្វផ្សាយតាមសហគមន៍ជាមួយនឹងការបណ្តុះបណ្តាល និងបំពាក់ឧបករណ៍	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតតំណភ្ជាប់ទៅនឹងកម្មវិធីផ្នែកការអប់រំផ្លូវចិត្ត និងលើកកម្ពស់ជីវភាពរស់នៅ	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ សុខភាពផ្លូវចិត្ត និងគាំទ្រផ្លូវចិត្ត	▪ ៦៥% នៃបុគ្គលិកជួរមុខបានទទួលការបណ្តុះបណ្តាលក្នុងការប្រឹក្សា និងនីតិវិធីនៃការបញ្ជូនបន្ត	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បុគ្គលិកបានបណ្តុះបណ្តាល និងជូនដំណឹងអំពីយន្តការបញ្ជូនដោយណែនាំប្រាស់លាស់ដល់អ្នកជំនាញផ្នែកសុខភាពផ្លូវចិត្ត	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បុគ្គលិកបានបណ្តុះបណ្តាល និងជូនដំណឹងអំពីក្រុមគាំទ្រជនរងគ្រោះ និងបណ្តាញអ្នកស្ម័គ្រចិត្ត	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំសកម្មភាពសហគមន៍ ដើម្បីកាត់បន្ថយការមាក់ងាយ និងលើកកម្ពស់ការធ្វើបរិយាបន្ន	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សហការជាមួយអ្នកដឹកនាំប្រពៃណី និងសហគមន៍ ដើម្បីពង្រឹងបណ្តាញគាំទ្រ	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ការធ្វើបរិយាបន្ន សេដ្ឋកិច្ច សង្គម	▪ ផ្តល់ជូននូវកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈចម្រុះដោយផ្អែកលើតម្រូវការទីផ្សារ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ ផ្តល់ឥណទាន ឬជំនួយឥតសំណងសម្រាប់បង្កើតអាជីវកម្មខ្នាតតូច	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំកម្មវិធីយេនឌ័រ និងឱ្យស្របអាយុ ភេទ សម្រាប់ជនរងគ្រោះ និងគ្រួសារ	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធ្វើការជាមួយអាជីវកម្មក្នុងស្រុកដើម្បីបង្កើនឱកាសការងារ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ គាំទ្រអ្នកថែទាំគ្រួសារតាមរយៈការបណ្តុះបណ្តាល និងផ្តល់សេវាកម្ម	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ច្បាប់ និង គោលនយោបាយ	▪ គាំទ្រការអនុវត្តច្បាប់ និងគោលនយោបាយស្តីពីពិការភាព	ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ត្រួតពិនិត្យការអនុលោមតាមសន្ធិសញ្ញាអន្តរជាតិ និងស្តង់ដាសិទ្ធិមនុស្ស	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ គាំទ្រអង្គការជនពិការ ដើម្បីចូលរួមក្នុងការបង្កើតគោលនយោបាយ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើនការចូលរួមរបស់ជនរងគ្រោះក្នុងការពិភាក្សាច្បាប់ និងគោលនយោបាយ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី៤៖ ក្របខ័ណ្ឌច្បាប់ សម្រាប់ការអនុវត្ត		▪ រាល់មុខតំណែងជាអ្នកគ្រប់គ្រង និងជាអ្នកដឹកនាំបានអានស្តង់ដាអន្តរជាតិ ១៣.១០	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ ៦០% នៃបុគ្គលិកអាន ឬទទួលបានការបណ្តុះបណ្តាលស្តីពីស្តង់ដាអន្តរជាតិ និងស្តង់ដាជំពូកទី២៣	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ពិនិត្យឡើងវិញនូវច្បាប់ស្តីពីពិការភាព និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បណ្តុះបណ្តាលដល់បុគ្គលិកអំពីវិធីសាស្ត្រផ្អែកលើសិទ្ធិ និងការអនុវត្តរួម	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធានាថាឧបករណ៍បរិក្ខារ និងកម្មវិធីបំពេញតាមស្តង់ដាដោយស្របតាមច្បាប់ និងគោលនយោបាយស្តីពីពិការភាពកម្ពុជា	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ចូលរួមក្នុងកិច្ចប្រជុំសម្របសម្រួលដើម្បីផ្តល់សេវាកម្មជាមួយផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ	គ្រប់ភាគីពាក់ព័ន្ធ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី៥ ៖ វិធីសាស្ត្រពហុវិស័យ	**▪ ថែទាំសុខភាព និងវេជ្ជសាស្ត្រ**	▪ ៦០% នៃអ្នកឆ្លើយតបជំងឺបងរបស់សហគមន៍ទទួលការបណ្តុះបណ្តាលពីការថែទាំរបួសជាមូលដ្ឋាន និងយន្តការបញ្ជូនបន្ត	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ មានផែនការដឹកជញ្ជូនបន្ទាន់សហគមន៍នៅក្នុង ៧០% នៃភូមិដែលមានហានិភ័យខ្ពស់	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ មានបញ្ជីរាយនាមកន្លែងថែទាំសុខភាពក្នុងស្រុកដែលបានធ្វើបច្ចុប្បន្នភាព ដោយចែករំលែកជាមួយអាជ្ញាធរមីន	ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំផែនការយុទ្ធនាការសម្រាប់ជនរងគ្រោះនិងក្រុមគ្រួសារអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ឬឧបត្ថម្ភធន	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

	▪ **ការស្តារលទ្ធភាពពលកម្ម**	▪ ៧០% នៃជនរងគ្រោះមានតម្រូវការស្តារលទ្ធភាពពលកម្មកាយសម្បទាចំពោះការទទួលបានសេវាកម្មសមស្របបន្ទាប់ពីការចេញពីមន្ទីរពេទ្យ	ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំផ្តល់សេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទាចល័តប្រចាំត្រីមាសទៅតំបន់ដាច់ស្រយាល	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បណ្តុះបណ្តាល ៧០% នៃអ្នកថែទាំគ្រួសារពីបច្ចេកទេសមូលដ្ឋាននៃការស្តារលទ្ធភាពពលកម្មកាយសម្បទា	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ មានសិទ្ធិចូលប្រើប្រាស់ ឬអភិវឌ្ឍមូលដ្ឋានទិន្នន័យថ្នាក់តំបន់នៃគ្រឿងឧបករណ៍ និងសេវាកម្មជំនួយ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **គាំទ្រផ្លូវចិត្ត និងចិត្តសង្គម**	▪ បណ្តុះបណ្តាល ៦០% នៃបុគ្គលិកទីវាលពីបច្ចេកទេសមូលដ្ឋានពីការគាំទ្រផ្លូវចិត្ត	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើត (ឬមានព័ត៌មានទំនាក់ទំនង) សម្រាប់ជួយគាំទ្រមិត្តរួមការងារសកម្មនៅក្នុងតំបន់ ឬខេត្ត	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំ ឬផ្សព្វផ្សាយអប្បរមានៃការជាប់បញ្ចូលក្នុងសហគមន៍ និងព្រឹត្តិការណ៍ប្រឆាំងការមាក់ងាយចំនួនពីរដងក្នុងមួយឆ្នាំ	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ភ្ជាប់ ៨០% នៃជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណជាមួយនឹងតម្រូវការផ្នែកផ្លូវចិត្តទៅនឹងសេវាកម្មសមស្របក្នុងរយៈពេល ៦ ខែបន្ទាប់ពីការរងរបួសដំបូង	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ការធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម**	▪ ចុះឈ្មោះ (ឬបញ្ចាក់) ៥០% នៃជនរងគ្រោះពេញវ័យទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈមានទីផ្សារ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ ផ្តល់ជំនួយពេលចាប់ផ្តើមអាជីវកម្ម ឬកម្ចីខ្នាតតូច ឬបញ្ចាក់ការចូលប្រើប្រាស់យ៉ាងតិច ៣០% នៃជនរងគ្រោះដែលប្រកបមុខរបរខ្លួនឯង	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំសិក្ខាសាលាដើម្បីព័ត៌មានអំពីការងារប្រចាំឆ្នាំសម្រាប់អាជីវកម្មក្នុងស្រុក	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធានាបាននូវការចូលរួមឱ្យបាន ៤០% ជាស្ត្រីក្នុងកម្មវិធីមុខរបរចិញ្ចឹមជីវិត	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ការអប់រំបណ្តុះបណ្តាលនិងការងារ	▪ ចុះឈ្មោះចូលរៀនឡើងវិញ ៧០% នៃជនរងគ្រោះពីអាយុសិក្សាក្នុងការធ្វើបរិយាបន្នអប់រំដោយរួមបញ្ចូលជាមួយនឹងការគាំទ្រតាមតម្រូវការ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បើកដំណើរការ ឬដឹងអំពីកម្មវិធីវិជ្ជាជីវៈ ដែលត្រូវនឹងតម្រូវការទីផ្សារក្នុងស្រុក	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សហការជាមួយក្រសួងការងារ រំអាជីវកម្មក្នុងស្រុក ដើម្បីជ្រើសរើសជនរងគ្រោះធ្វើការបណ្តុះបណ្តាលការងារ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ គាំទ្រ ៤០% នៃជនរងគ្រោះដែលត្រូវបានបណ្តុះបណ្តាលដើម្បីបើកដំណើរការអាជីវកម្មខ្នាតតូច	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ការផ្តល់អំណាច	▪ បង្កើត ឬដឹងអំពីបណ្តាញដែលដឹកនាំដោយជនរងគ្រោះនៅតាមបណ្តាខេត្ត	អាជ្ញាធរមីន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ផ្តល់ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំប្រចាំឆ្នាំដែលឈានដល់ ៧៥% នៃជនរងគ្រោះដែលសកម្ម	អាជ្ញាធរមីន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ ផ្តល់ការបណ្តុះបណ្តាលតស៊ូមតិប្រចាំឆ្នាំដែលឈានដល់ ៥០% នៃជនរងគ្រោះដែលសកម្ម	អាជ្ញាធរមីន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធានា ឬបញ្ជាក់តំណាងជនរងគ្រោះនៅក្នុងវេទិកាដែលរៀបចំផែនការឃុំ សង្កាត់	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សម្រេចបានការចូលរួម ៦០% ជាស្ត្រីជនរងគ្រោះក្នុងសកម្មភាពផ្តល់អំណាច	អាជ្ញាធរមីន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ប្រព័ន្ធការពារសង្គម	▪ ចុះឈ្មោះ ៧០% នៃជនរងគ្រោះដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍សង្គម	ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បណ្តុះបណ្តាល ៧០% នៃបុគ្គលិកទីវាលពីសិទ្ធិជនពិការ និងនីតិវិធីគាំពារសង្គម	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ជំរើរការយុទ្ធនាការផ្សព្វផ្សាយដើម្បីអប់រំសហគមន៍អំពីសិទ្ធិរបស់ជនរងគ្រោះ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សម្រេចបានសមភាពយេនឌ័រក្នុងការទទួលអត្ថប្រយោជន៍នៃអ្នកទទួលថ្មីជាស្ត្រី	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ជំនួយផ្នែកច្បាប់	▪ ជំរើរការបញ្ជូនជនរងគ្រោះដែលមានបញ្ហាផ្នែកច្បាប់	អង្គការ/អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សហការជាមួយអ្នកផ្តល់ជំនួយផ្នែកច្បាប់ចំនួន ៣ នៅក្នុងខេត្តនីមួយៗ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ ធ្វើការបណ្តុះបណ្តាលសិទ្ធិស្របច្បាប់ឱ្យបាន ៥០% នៃជនរងគ្រោះ និងគ្រួសារ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី៦៖ ការសម្របសម្រួល និងកិច្ចសហការ	▪ **តាពជាអ្នកដឹកនាំ និង តាពជាម្ចាស់**	▪ អាជ្ញាធរមីននឹងដឹកនាំកិច្ចប្រជុំសម្របសម្រួលដែលពាក់ព័ន្ធនឹងក្រសួង និងដៃគូ ដើម្បីធានាថាសេវាកម្មបានអនុវត្តតាមផែនការយុទ្ធសាស្ត្រ និងគោលនយោបាយជាតិ	អាជ្ញាធរមីន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ភាគីពាក់ព័ន្ធនឹងត្រូវបានផ្តល់ជូនព័ត៌មានពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរគោលនយោបាយ ឬការអនុវត្ត	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ តាមខេត្តនឹងអនុម័ត និងដាក់បញ្ចូលផែនការកិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ជាតិ ក្នុងការផ្តល់សេវាកម្ម	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ការត្រួតពិនិត្យប្រចាំឆ្នាំធ្វើឡើងដោយអាជ្ញាធរមីន លើការត្រួតពិនិត្យនៃការអនុលោមតាមវិស័យពាក់ព័ន្ធ	អាជ្ញាធរមីន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **តាពជាដៃគូរនាងរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល**	▪ ៩០% នៃអង្គការក្រៅរដ្ឋាភិបាល នឹងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូជាមួយភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ទិន្នន័យសេវាកម្មរបស់អង្គការមិនមែនរដ្ឋាភិបាលនឹងត្រូវបានជាក់ជូនជារៀងរាល់ត្រីមាស ទៅកាន់ប្រព័ន្ធកិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ជាតិ ដើម្បីគាំទ្រដល់ការរៀបចំផែនការ	អង្គការ អាជ្ញាធរមីន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សិក្ខាសាលាបណ្តុះបណ្តាលរួមគ្នាចំនួនពីរនឹងធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីបង្កើនជំនាញ និងការសម្របសម្រួលរវាងបុគ្គលិករដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ យុទ្ធនាការផ្សព្វផ្សាយរួមគ្នានឹងត្រូវបានអនុវត្តនៅតាមខេត្ត ដើម្បីពង្រីកលទ្ធភាព	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

	▪ **ការចូលរួមសហគមន៍**	▪ វេទិកាមតិកែលម្អរបស់សហគមន៍នឹងធ្វើឡើងនៅក្នុងស្រុកខេត្តគោលដៅ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បណ្តាញដែលដឹកនាំដោយជនរងគ្រោះនឹងត្រូវបានគាំទ្រ និងបណ្តុះបណ្តាលជារៀងរាល់ឆ្នាំ	អាជ្ញាធរមីន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ អ្នកតំណាងជនរងគ្រោះនឹងត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចប្រជុំរៀបចំផែនការតាមស្រុក ដើម្បីធានាថាទស្សនៈរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំង	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ៥០% នៃអ្នកដឹកនាំមូលដ្ឋាននឹងបញ្ចប់ការបណ្តុះបណ្តាលលើបច្ចេកទេសលើកកម្ពស់ការធ្វើបរិយាបន្ន	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **យន្តការបញ្ជូន**	▪ បញ្ជីរាយនាមនឹងត្រូវបានបង្កើត និងចែកចាយគ្រប់ខេត្ត	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បញ្ជីរាយនាមបានធ្វើបច្ចុប្បន្នភាពរៀងរាល់៦ខែម្តង	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ៦០% នៃបុគ្គលិកនៅតាមទីវាលត្រូវបានបណ្តុះបណ្តាលពីយន្តការបញ្ជូន	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ មតិឆ្លើយតបពីភ្នាក់ងារនឹងត្រូវបានប្រមូលសម្រាប់ការបញ្ជូនបន្ត ដើម្បីធានាថាជនរងគ្រោះទទួលបានការគាំទ្រត្រឹមត្រូវ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ប្រព័ន្ធគ្រប់គ្រងករណី**	▪ ចាត់តាំង (បញ្ជាក់បានចាត់តាំង) អ្នកគ្រប់គ្រងសំណុំរឿងទៅគ្រប់ករណី ដោយកំណត់អត្តសញ្ញាណ ដើម្បីធានាឱ្យមានអន្តរាគមន៍ទាន់ពេល	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ បណ្តុះបណ្តាលអ្នកគ្រប់គ្រងករណីសកម្មពីបច្ចេកទេសរៀបចំផែនការដែលផ្តោតលើជនរងគ្រោះ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំកិច្ចប្រជុំសម្របសម្រួលនៅស្រុកគោលដៅ ដើម្បីពិនិត្យ និងរៀបចំផែនការគាំទ្រជនរងគ្រោះ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ សម្រេចបាន ៧០% ការចូលរួមរបស់ជនរគ្រោះក្នុងការសម្រេចចិត្តក្នុងអំឡុងពេលដំណើរការរៀបចំផែនការថែទាំ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ការចែករំលែកព័ត៌មាន និងទិន្នន័យ	▪ អនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យដោយបែងចែកភេទ អាយុ និងពិការភាព ដើម្បីធ្វើរបាយការណ៍ឱ្យជាលក្ខណៈស្តង់ដា	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធានាការចែករំលែកទិន្នន័យ និងកិច្ចព្រមព្រៀងរក្សាការសម្ងាត់ពីដៃគូសកម្ម	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បញ្ជូនទិន្នន័យសេវាកម្មប្រចាំត្រីមាសដែលមិនបញ្ចេញឈ្មោះពីគ្រប់ស្រុកទៅអាជ្ញាធរមីន	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ផ្តល់ការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងទិន្នន័យប្រកបដោយក្រមសីលធម៌ (ដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះ) ដល់បុគ្គលិកជួរមុខដែលប្រមូល និងរក្សាទិន្នន័យ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ មតិកែលម្អ និងការឆ្លុះបុសត្រូវ	▪ រៀបចំយន្តការទទួលមតិកែលម្អដែលអាចចូលដំណើរការតាមស្រុកប្រតិបត្តិការ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ដោះស្រាយ និងឆ្លើយតប ពាក្យបណ្តឹងផ្លូវការ ឬមតិកែលម្អ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ ធ្វើការស្ទង់មតិការពេញចិត្តរបស់ជនរងគ្រោះដែលមានរចនាសម្ព័ន្ធនៅតាមខេត្ត ដើម្បីតាមដានគុណភាពសេវាកម្ម	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រាយការណ៍ជាសាធារណៈអំពីសកម្មភាពដែលបានមកពីមតិកែលម្អនៅក្នុងកិច្ចប្រជុំសហគមន៍ដែលបានធ្វើឡើងនៅតាមខេត្ត	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ ការធ្វើផែនការរួម និងធនធាន	▪ បំពេញផែនការសកម្មភាពរួមថ្នាក់ស្រុកគ្រប់ខេត្តគោលដៅ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំវេទិកាថ្នាក់ជាតិប្រចាំឆ្នាំដែលដឹកនាំដោយអាជ្ញាធរមីន	អាជ្ញាធរមីន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធានាថាក្រុមដឹកនាំដោយជនរងគ្រោះត្រូវបានរួមបញ្ចូលក្នុងកិច្ចប្រជុំ និងគម្រោងផ្តល់មូលនិធិ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី៧៖ បញ្ហាប្រឈម និងទិសដៅបន្ត	**▪ ដោះស្រាយបញ្ហាប្រឈម**	▪ ធ្វើសវនកម្មលទ្ធភាពប្រើប្រាស់នៃការស្តារលទ្ធភាពពលកម្មកាយសម្បទា និងបរិក្ខារនៃកិច្ចសង្គ្រោះជនរងគ្រោះ ដើម្បីកំណត់អត្តសញ្ញាណ និងដកចេញនូវរបាំងផ្នែករាងកាយ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើត និងអនុវត្តយុទ្ធនាការប្រឆាំងការមាក់ងាយនៅគ្រប់ខេត្តដែលរងផលប៉ះពាល់ជារៀងរាល់ឆ្នាំ ដើម្បីដោះស្រាយការជើសអើង	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើនការជាប់បញ្ចូល OPDs ក្នុង ៦៥% នៃវេទិកាបង្កើតគោលនយោបាយ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតក្រុមសម្របសម្រួលអន្តរភ្នាក់ងារនៅខេត្តគោលដៅ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

	▪ **ដោះស្រាយតម្រូវការកើតមានថ្មីៗ**	▪ ធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្រូវការជនរងគ្រោះដើម្បីជាក់រួមបញ្ចូលតំបន់ដែលរងផលប៉ះពាល់ដោយសារយុទ្ធកណ្តាក្រឿងផ្ទុះថ្មី	អាជ្ញាធរមីន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ការប្តេជ្ញាចិត្តផ្តល់មូលនិធិប្រកបដោយសុវត្ថិភាពសម្រាប់ការជំនួសគ្រឿងឧបករណ៍ជំនួយសម្រាប់ជនរងគ្រោះ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ពង្រីកកម្មវិធីជំនួយសុខភាពផ្លូវចិត្ត និងមិត្តអប់រំមិត្តដល់សហគមន៍ថ្មី	អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីកិច្ចសង្គ្រោះជនរងគ្រោះ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ការលើកកម្ពស់នខានុវត្ត**	▪ បើកដំណើរការ ឬផ្សព្វផ្សាយសេវាប្រឹក្សាសុខភាពចល័តនៅតាមខេត្តដែលរងផលប៉ះពាល់	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បណ្តុះបណ្តាលបុគ្គលិកស្តារលទ្ធភាពពលកម្មកាយសម្បទាក្នុងការរចនា និងផលិតអវៈយវៈសិប្បនិម្មិត	ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ផ្តល់ជំនួយក្នុងការចាប់ផ្តើមអាជីវកម្មខ្នាតតូចដល់ជនរងគ្រោះ	ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ចូលរួមបណ្តាញចែករំលែកចំណេះដឹងពីកិច្ចសង្គ្រោះជនរងគ្រោះអន្តរជាតិ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
	▪ **ការចូលរួមក្នុងតំបន់និងសកល**	▪ ធ្វើជាម្ចាស់ផ្ទះ ឬចូលរួមក្នុងព្រឹត្តិការណ៍សម្របសម្រួលថ្នាក់តំបន់នៅលើផ្នែកកិច្ចសង្គ្រោះជនរងគ្រោះ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ បកប្រែក្របខ័ណ្ឌកិច្ចសង្គ្រោះជនរងគ្រោះ ទៅជាភាសាអង់គ្លេស និងចែករំលែកជាមួយដៃគូអន្តរជាតិ	អាជ្ញាធរមីន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ កែសម្រួលគ្រឿងឧបករណ៍អនុវត្តល្អបំផុតអន្តរជាតិទៅក្នុងប្រព័ន្ធថ្នាក់ជាតិ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ គាំទ្រអ្នកអនុវត្តកិច្ចសង្គ្រោះជនរងគ្រោះ ចូលរួមសន្និសីទពិភពលោក	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី៨៖ ការត្រួតពិនិត្យ និងការវាយតម្លៃ	▪ **បញ្ជីត្រួតពិនិត្យតាមដាន និងវាយតម្លៃ**	▪ បង្កើត និងចែកសេចក្តីណែនាំអំពីការត្រួតពិនិត្យ និងវាយតម្លៃទៅកាន់ក្រុមទីវាល	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំកាលវិភាគប្រមូលទិន្នន័យជាប្រចាំ (ប្រចាំខែ ឬត្រីមាស)	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រួមបញ្ចូលមតិកែលម្អរបស់ជនរងគ្រោះនៅក្នុងការវាយតម្លៃ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ អាជ្ញាធរមីនរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីកម្មវិធីគាំទ្រដល់ជនរងគ្រោះ	អាជ្ញាធរមីន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំកិច្ចប្រជុំត្រួតពិនិត្យជាមួយអ្នកផ្តល់សេវា និង OPDs	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បញ្ចប់ និងអនុម័តសូចនាករនៃកិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ជាតិ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ បណ្តុះបណ្តាលបុគ្គលិកទីវាលនៅក្នុងប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ និងយន្តការប្រមូលទិន្នន័យ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ មានរបាយការណ៍ប្រចាំត្រីមាសពីគ្រប់គេហទំព័រ	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រួមបញ្ចូលទិន្នន័យដែលញែកចេញពីរបាយការណ៍ថ្នាក់ស្រុក	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ធ្វើការត្រួតពិនិត្យវាយតម្លៃជាផ្លូវការនៃកម្មវិធីសំខាន់ៗ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ប្រើប្រាស់ទិន្នន័យទាំងបរិមាណ និងគុណភាពក្នុងការវាយតម្លៃ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រួមបញ្ចូលជនរងគ្រោះ និងការចូលរួមរបស់ OPD ក្នុងការវាយតម្លៃ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ចែករំលែកលទ្ធផលវាយតម្លៃក្នុងកិច្ចប្រជុំសាធារណៈ ឬកាគីពាក់ព័ន្ធ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រកម្មវិធីដោយផ្អែកលើការរកឃើញការត្រួតពិនិត្យ និងវាយតម្លៃ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្ហាញការរកឃើញពីរបាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាសដល់សហគមន៍	ក្រសួង ស្ថាប័ន អង្គការ អ្នកផ្តល់សេវា	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់

		▪ សង្ខេបរបាយការណ៍នៃការត្រួតពិនិត្យ និងវាយតម្លៃជាសាធារណៈសម្រាប់ជនរងគ្រោះ និងគ្រួសារ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បញ្ចូលលទ្ធផលត្រួតពិនិត្យ និងវាយតម្លៃទៅក្នុងដំណើរការរៀបចំផែនការថ្នាក់ជាតិប្រចាំឆ្នាំ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
ជំពូកទី៩៖ សេចក្តីសន្និដ្ឋាន និងការអំពាវនាវ		▪ ធានាថាគ្រប់ថ្នាក់ដឹកនាំនៃស្ថាប័នពាក់ព័ន្ធបានបង្ហាញការប្តេជ្ញាចិត្តនយោបាយក្នុងការអនុវត្តគោលការណ៍ណែនាំជាតិ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតផែនការអំពាវនាវ និងកៀរគរថវិកាពីដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីបំពេញចន្លោះខ្វះខាតផ្នែកហិរញ្ញវត្ថុ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ អនុវត្តការតស៊ូមតិដើម្បីឱ្យមានការវិភាជថវិកាជាតិកាន់តែច្រើន និងមានស្ថិរភាពសម្រាប់វិស័យកិច្ចសង្គ្រោះជនរងគ្រោះ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន អង្គការ	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ រៀបចំកម្មវិធីផ្សព្វផ្សាយថ្នាក់ជាតិដើម្បីជាក់ឱ្យប្រើប្រាស់របាយការណ៍លទ្ធផលរួម និងអំពាវនាវឱ្យមានការចូលរួមជាសកល	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់
		▪ បង្កើតយន្តការតាមដានការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធ ដើម្បីធានាថាសកម្មភាពគាំទ្រជនរងគ្រោះនៅតែជាអាទិភាព ទោះបីជាគម្រោងនីមួយៗត្រូវបញ្ចប់ក៏ដោយ	អាជ្ញាធរមីន ក្រសួង ស្ថាប័ន	□ រួចរាល់ □ កំពុងធ្វើ □ មិនទាន់